00983188

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

**ឯកសារលេខ: D87/2/2**

*ក្នុងនាមប្រជារាស្ត្រខ្មែរ និងក្នុងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៣/០៧-០៩-២០០៩-អវតក/កសចស (អបជ ១០)

ចំពោះមុខ: ចៅក្រម ប្រាក់ គីមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន៉ី ថុល
ចៅក្រម Chang-Ho CHUNG
ចៅក្រម ហួត វុធី

កាលបរិច្ឆេទ: ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៤

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 01 / 08 / 2014
ម៉ោង (Time/Heure): 10:45
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Sann Rada

---

**សាធារណៈ: (សំណៅកោសលុប)**

**សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងការបដិសេធតាមការសន្មត របស់សហចៅក្រមស៊ើបអង្កេត ទៅលើសារណារបស់ [redacted] ចំនួនដប់បួនច្បាប់ ដែលបានដាក់ទៅ [ការិយាល័យសហចៅក្រមស៊ើបអង្កេត]**

---

**សហព្រះរាជអាជ្ញា:**

ជា លាង
Nicholas KOUMJIAN

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី:**

ហុង គីមសួន
គីម ម៉េងឃី
សំ សុគង់
Annie DELAHAIE

**សហមេធាវីការពារក្តី [redacted]**

អាង ឧត្តម
Michael KARNAVAS

**សហចៅក្រមស៊ើបអង្កេត:**

យូ ប៊ុនឡេង
Mark B. HARMON

00983189



Laure DESFORGES
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Nushin SARKARATI
Mahdev MOHAN

**អង្គបុរេជំនុំជម្រះ**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "បណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងការបដិសេធតាមការសន្មតរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសារណារបស់ [redacted] ចំនួនដប់បួនច្បាប់ ដែលបានដាក់ទៅ ក.ស.ច.ស" ដែលបានដាក់ដោយ អាង ឧត្តម និង Michael G. KARNAVAS ("សហមេធាវី") ក្នុងនាម [redacted] នៅថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ("បណ្តឹងឧទ្ធរណ៍")[1]។

## I. **សាវតារ**

1. នៅថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទីកាលពីពេលនោះ បានដាក់ជូនសហចៅក្រមស៊ើបអង្កេតអន្តរជាតិ នូវដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ២ ទាក់ទងទៅ [redacted] ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ") ដែលបានធ្វើឱ្យមានកិច្ចស៊ើបសួរទៅលើ *ក្នុងចំណោមប្រការផ្សេងទៀត* ឧក្រិដ្ឋកម្មនានាដែល [redacted] ត្រូវបានចោទប្រកាន់ថាមានការទទួលខុសត្រូវ[2]។

2. នៅថ្ងៃទី ៦ ខែ មីនា ឆ្នាំ ២០១២ អង្គភាពគាំពារការការពារក្តី ("អ.គ.ក") ត្រូវបានបង្គាប់ឱ្យជួយដល់ [redacted] ក្នុងការជ្រើសរើសមេធាវីមួយរូបដើម្បីតំណាងឱ្យគាត់[3]។ នៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១២ ប្រធាន អ.គ.ក បានជូនដំណឹងដល់ការិយាល័យសហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស") ថា [redacted] បានជ្រើសយកលោក អាង ឧត្តម និងលោក Michael Karnavas ជាសហមេធាវីរបស់គាត់ ("សហមេធាវី") និងសូមឱ្យ ក.ស.ច.ស ទទួលជ្រាបអំពីការចាត់តាំងពួកគាត់នេះ[4]។ នៅថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១២ សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើឱ្យ ក.ស.ច.ស

---

[1] បណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងការបដិសេធតាមការសន្មតរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសារណារបស់ [redacted] ចំនួនដប់បួនច្បាប់ ដែលបានដាក់ទៅ ក.ស.ច.ស ថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣។

[2] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២ របស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹង [redacted] ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ឯកសារ D1។ សូមមើលផងដែរ សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី អំពីការដាក់ឯកសារស្តីពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី២ ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ ឯកសារ D1/1។

[3] ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ (វិធានផ្ទៃក្នុង ២១(១)(ឃ)) ទៅកាន់អង្គភាពគាំពារការការពារក្តី ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១២ ឯកសារ D33។

[4] លិខិតផ្ញើជូនសហចៅក្រមស៊ើបអង្កេត ស្តីអំពីការចាត់តាំងសហមេធាវីឱ្យធ្វើជាតំណាងលោក [redacted] ដែលជាជនសង្ស័យក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១២ ឯកសារ D56។

បដិសេធការចាត់តាំងសហមេធាវីតំណាង [redacted] ដោយចោទប្រកាន់អំពីបញ្ហាទំនាស់ផលប្រយោជន៍ដែលមិនអាចផ្សះផ្សាបាន (“សំណើរបស់សហព្រះរាជអាជ្ញា”)[5]។ បន្ទាប់ពីមានសំណើរបស់សហព្រះរាជអាជ្ញា នៅថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៣ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបង្គាប់ឱ្យសហមេធាវី និងសហការីរបស់ពួកគាត់ “ផ្អាកការប្រាស្រ័យទាក់ទង” ជាមួយនឹង [redacted] រហូតដល់មានការចេញសេចក្តីសម្រេចបញ្ជាក់អំពីការចាត់តាំងពួកគាត់ (“សេចក្តីសម្រេច និងដីកាកំណត់កាលបរិច្ឆេទ ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៣”)[6]។ នៅថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចទទួលយកសំណើ និងយល់ស្របតាមសំណើរបស់សហព្រះរាជអាជ្ញាបដិសេធការតែងតាំងសហមេធាវីតំណាងឱ្យ [redacted] និងបង្គាប់ឱ្យ អ.គ.ក ចាត់វិធានការចាំបាច់ដើម្បីចាត់តាំងសហមេធាវីថ្មី តំណាងឱ្យ [redacted] ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបានជាក់ស្តែង (“ដីកាសម្រេចពាក់ព័ន្ធនឹងទំនាស់”)[7]។ នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៤ សហមេធាវី ក្នុងនាម [redacted] បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ ដោយបញ្ជាក់អំពីចេតនារបស់ពួកគាត់ក្នុងការប្តឹងឧទ្ធរណ៍ទៅនឹងដីកាសម្រេចពាក់ព័ន្ធនឹងទំនាស់នេះនៅចំពោះមុខអង្គបុរេជំនុំជម្រះ[8]។ នៅថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៤ អង្គបុរេជំនុំជម្រះបានប្រកាស “ថា ការកំណត់ពេលវេលាណាមួយដើម្បីដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច [ពាក់ព័ន្ធនឹងទំនាស់] ត្រូវបានផ្អាក រហូតទាល់តែមានការចេញ និងការទទួលបានសេចក្តីសម្រេចបច្ចុប្បន្ននេះសិន” និង “ពន្យារការចេញសេចក្តីសម្រេចរបស់ខ្លួនទៅលើសំណើ [ពីសហមេធាវី] សុំសិទ្ធិចូលពិនិត្យមើលសំណុំរឿង រហូតដល់ពេលអង្គបុរេជំនុំជម្រះទទួលបានព័ត៌មានថា [redacted] មានបំណងបន្តការប្តឹងឧទ្ធរណ៍”[9]។ នៅថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០១៤ តាមរយៈសហមេធាវី

---

[5] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យបដិសេធការតែងតាំងសហមេធាវីចាត់តាំង ដោយផ្អែកលើមូលដ្ឋាននៃទំនាស់ផលប្រយោជន៍ដែលមិនអាចផ្សះផ្សាបាន ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១២ ឯកសារ D56/1។

[6] សេចក្តីសម្រេច និងដីកាកំណត់កាលបរិច្ឆេទពាក់ព័ន្ធសំណើសុំតែងតាំងសហមេធាវីចាត់តាំង ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ D56/3។

[7] ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឱ្យបដិសេធការតែងតាំងសហមេធាវីដែលត្រូវបានចាត់តាំង ដោយផ្អែកលើមូលដ្ឋានទំនាស់ផលប្រយោជន៍ដែលមិនអាចផ្សះផ្សាបាន ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៤ ឯកសារ D56/18។

[8] ការសុំប្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលស្នើឱ្យបដិសេធការតែងតាំងសហមេធាវីការពារក្តី [redacted] ដោយផ្អែកលើមូលដ្ឋានទំនាស់ផលប្រយោជន៍ដែលមិនអាចផ្សះផ្សា បាន ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៤ ឯកសារ D56/19។

[9] សេចក្តីសម្រេចលើសំណើសុំឱ្យមានវិធានការបណ្តោះអាសន្ន ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៤ ឯកសារ D56/19/8។

[redacted] បានដាក់សេចក្តីជូនដំណឹងរបស់គាត់ស្តីពីចេតនាប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចពាក់ព័ន្ធនឹងទំនាស់ នៅចំពោះមុខអង្គបុរេជំនុំជម្រះ[10] ដោយបញ្ជាក់ឡើងវិញអំពីគោលបំណងចង់ឱ្យសហមេធាវីទាំងពីរធ្វើជាតំណាងរូបគាត់[11]។ នៅថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៤ សហមេធាវីបានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចអំពីទំនាស់។ ដំណើរការជាលាយល័ក្ខអក្សរនៃបណ្តឹងឧទ្ធរណ៍នេះ កំពុងតែប្រព្រឹត្តទៅ ដូចមានចែងក្នុងវិធានផ្ទៃក្នុង។

3. នៅក្នុងខណៈដែលបញ្ហានៃការតែងតាំងសហមេធាវីតំណាងឱ្យ [redacted] កំពុងស្ថិតនៅក្រោមការពិចារណា ហើយ*ការប្រាស្រ័យទាក់ទងរវាងសហមេធាវី និង* [redacted] *ត្រូវបានផ្អាក* នោះ នៅចន្លោះថ្ងៃទី ២៩ ខែ សីហា និងថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៣ សហមេធាវី ក្នុងនាម [redacted] បានដាក់សារណាចំនួន ១៤ ជូនទៅសហចៅក្រមស៊ើបអង្កេត ("សារណាចំនួន១៤")[12]។ នៅថ្ងៃទី

---

[10] សេចក្តីជូនដំណឹងរបស់ [redacted] ស្តីពីចេតនាប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិឱ្យច្រានចោលការតែងតាំងសហមេធាវីរបស់ [redacted] ដោយផ្អែកលើមូលដ្ឋានទំនាស់ផលប្រយោជន៍ដែលមិនអាចផ្សះផ្សាបាន ថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D56/19/13។

[11] ឯកសារ D56/19/13.1។

[12] សំណើរបស់ [redacted] ស្នើសុំការអនុញ្ញាតចូលពិនិត្យសំណុំរឿង និងចូលរួមក្នុងការស៊ើបអង្កេតតាមផ្លូវតុលាការ ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ D82 និង D87/2/1.2។ សំណើសុំព័ត៌មាន ពាក់ព័ន្ធនឹងរបៀប និងវិធីសាស្ត្រស៊ើបអង្កេតរបស់ ក.ស.ច.ស ថ្ងៃទី ២ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ D87/2/1.3។ សេចក្តីជូនដំណឹងរបស់លោក [redacted] ពីការជំទាស់ទៅនឹងការចូលរួម ពាក់ព័ន្ធបន្ថែមទៀត របស់លោក STEPHEN HEDER នៅក្នុងសំណុំរឿង ០០៣ និង សំណើសុំលទ្ធផលការងាររបស់លោក STEPHEN HEDER ថ្ងៃទី ៩ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ D87/2/1.4។ សេចក្តីជូនដំណឹងរបស់ [redacted] ពីការជំទាស់ទៅនឹងការចូលរួម ពាក់ព័ន្ធបន្ថែមទៀតរបស់លោក David Boyle នៅក្នុងសំណុំរឿង ០០៣ និងសំណើសុំលទ្ធផលការងាររបស់លោក David Boyle ថ្ងៃទី ៩ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ D87/2/1.5។ សំណើរបស់ [redacted] ស្នើសុំឱ្យផ្តល់ជូននូវលិខិតឆ្លើយឆ្លងពីប្រធានផ្នែកច្បាប់របស់ ក.ស.ច.ស ទៅកាន់អគ្គលេខាធិការអង្គការសហប្រជាជាតិ និងឯកសារពាក់ព័ន្ធទាំងអស់ និង ស្នើសុំឱ្យដាក់ឯកសារនេះទៅក្នុងសំណុំរឿង ថ្ងៃទី ៩ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ D872/1.6។ សំណើរបស់ [redacted] ស្នើសុំការស្រាយបំភ្លឺអំពីថាតើ ក.ស.ច.ស យល់ឃើញថា ខ្លួនឯងជាប់កាតព្វកិច្ច ដោយយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះដែលថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតម្រូវឱ្យមានទំនាក់ទំនងទៅនឹងជម្លោះប្រដាប់អាវុធ ឬយ៉ាងណា ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ D87/2/1.7។ សំណើរបស់ [redacted] សុំឱ្យ ក.ស.ច.ស ដាក់ប្រតិចារឹកទាំងស្រុងនៃកិច្ចសម្ភាសន៍ស្តាប់ចម្លើយសាក្សីទាំងអស់ទៅក្នុងសំណុំរឿង ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ D87/2/1.8 ។ សំណើរបស់ [redacted] ស្នើសុំលទ្ធផលការងាររបស់អ្នកស៊ើបអង្កេត ក.ស.ច.ស ដែលពាក់ព័ន្ធនឹងការអនុវត្តការស៊ើបអង្កេតមិនត្រឹមត្រូវនៅក្នុងសំណុំរឿង ០០២ ថ្ងៃទី ២ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ D87/2/1.9។ សំណើរបស់ [redacted] ស្នើសុំលក្ខណៈវិនិច្ឆ័យពាក់ព័ន្ធនឹង "មេដឹកនាំជាន់ខ្ពស់របស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ D87/2/1.10។ សំណើរបស់ [redacted] ស្នើសុំឱ្យ ក.ស.ច.ស បង្ខំឱ្យ ក.ស.ច.ស ផ្តល់ឱ្យមេធាវីការពារក្តីនូវ



E.C.C.C • C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE

២៥ ខែ តុលា ឆ្នាំ ២០១៣ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានជូនដំណឹងទៅសហមេធាវីថា "ដោយពិចារណាទៅលើលទ្ធភាព នៃការជាប់ពាក់ព័ន្ធនឹងការចោទប្រកាន់អំពីទំនាស់ផលប្រយោជន៍នៅក្នុង [*សំណើរបស់សហព្រះរាជអាជ្ញា*] សារណាដែលបានបញ្ជាក់ជូនខាងលើនោះនឹងត្រូវបានដោះស្រាយនៅក្នុងពេលវេលាសមស្រប ដោយយោងទៅលើលទ្ធផលនៃសេចក្តីសម្រេចលើបញ្ហា [ទំនាស់] នេះ"[13]។ នៅថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០១៣ សហមេធាវីបានដាក់នៅចំពោះមុខ ក.ស.ច.ស នូវ "សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធតាមការសន្និតរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសារណារបស់ [redacted] ចំនួនដប់បួនច្បាប់ដែលបានដាក់ទៅ ក.ស.ច.ស"[14]។ នៅថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ការជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ត្រូវបានជូនដំណឹង ហើយសំណុំរឿង ០០៣ ត្រូវបានបញ្ជូនបន្តទៅអង្គបុរេជំនុំជម្រះ តាមរយៈក្រឡាបញ្ជីរបស់ ក.ស.ច.ស ដែលបានជម្រាបជូនដូចខាងក្រោមនេះ ៖

> "សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានសម្រេចពន្យារពេលការដាក់ឯកសារចូលទៅក្នុងសំណុំរឿង និងពន្យារពេលការឆ្លើយតបទៅនឹងសារណាខាងលើ ដោយអនុលោមតាមវិធានផ្ទៃក្នុង ៥៥(១០) គឺត្រូវរង់ចាំដីកាសម្រេចលើការចោទប្រកាន់ជាផ្លូវការទៅលើជនសង្ស័យ ចំពោះការចោទប្រកាន់ថា គាត់បានចូលរួមនៅក្នុងឧក្រិដ្ឋកម្មដូចបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរ និងត្រូវរង់ចាំដីកាសម្រេចលើ*សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើឲ្យបដិសេធការតែងតាំងសហមេធាវីដែលត្រូវបាន*

---

លក្ខណៈវិនិច្ឆ័យរបស់ខ្លួន ពាក់ព័ន្ធនឹង "មេដឹកនាំជាន់ខ្ពស់របស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ D87/2/1.11។ សំណើរបស់ [redacted] ស្នើសុំការបញ្ជាក់ពាក់ព័ន្ធនឹងថាតើមេធាវីការពារក្តីអាចធ្វើការស៊ើបអង្កេតនៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនាពេលបច្ចុប្បន្ននេះឬយ៉ាងណា ថ្ងៃទី ២ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ D87/2/1.12។ ញត្តិរបស់ [redacted] ប្រឆាំងនឹងការអនុវត្តឧក្រិដ្ឋកម្មនានាដែលមានចែងនៅក្នុងមាត្រា ៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក (ឧក្រិដ្ឋកម្មដែលចែងក្នុងច្បាប់ជាតិ) ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ D87/2/1.13។ សំណើរបស់ [redacted] ស្នើសុំឲ្យ ក.ស.ច.ស ស្តាប់ចម្លើយសាក្សីឡើងវិញ ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ D87/2/1.14។ ញត្តិរបស់ [redacted] ប្រឆាំងនឹងការអនុវត្តសហឧក្រិដ្ឋកម្មរួមទម្រង់ទូលាយ (JCE III) ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ D87/2/1.15។

[13] លិខិតពី ក.ស.ច.ស ផ្ញើជូនមេធាវីការពារក្តី សារណាដែលបានដាក់ដោយសហមេធាវីដែលត្រូវបានចាត់តាំង នៅក្នុងសំណុំរឿង ០០៣ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ D87។

[14] សៀវភៅចុះបណ្តឹងឧទ្ធរណ៍ អំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធតាមការសន្និតរបស់សហចៅក្រមស៊ើបអង្កេតទៅលើសំណើសុំទាំង១៤ របស់លោក [redacted] ដែលបានដាក់ទៅ ក.ស.ច.ស ថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D87/2។

***សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងការបដិសេធតាមការសន្និតរបស់សហចៅក្រមស៊ើបអង្កេតទៅលើសារណារបស់ [redacted] ចំនួនដប់បួនច្បាប់ ដែលបានដាក់ទៅ[ការិយាល័យសហចៅក្រមស៊ើបអង្កេត]***

*តែងតាំង ដោយផ្អែកលើមូលដ្ឋានទំនាស់ផលប្រយោជន៍មិនអាចផ្សះផ្សាបាន* (សំណុំរឿង ០០៣ ឯកសារ D56/1 ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១២)។

ខ្ញុំបានទទួលសេចក្តីណែនាំពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដើម្បីជម្រាបជូនអង្គបុរេជំនុំជម្រះថា [សារណាខាងលើ] នឹងត្រូវប្រគល់ជូនអង្គបុរេជំនុំជម្រះ តាមសំណើ ប្រសិនបើអង្គបុរេជំនុំជម្រះ ត្រូវការសារណាទាំងនោះ ដើម្បីសម្រេចលើបណ្តឹងឧទ្ធរណ៍"[15]។

4. នៅថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣ សហមេធាវីបានដាក់បណ្តឹងឧទ្ធរណ៍ជាភាសាអង់គ្លេសប៉ុណ្ណោះ ដោយបណ្តឹងឧទ្ធរណ៍នេះត្រូវបានជូនដំណឹងនៅថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៣។ សំណៅបកប្រែជាភាសាខ្មែរនៃបណ្តឹងឧទ្ធរណ៍នេះ ត្រូវបានជូនដំណឹងនៅថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៣។

5. មិនមានការដាក់ចម្លើយតបពីភាគីណាមួយឡើយ នៅក្នុងរយៈពេលកំណត់តាមច្បាប់ឡើយ។

## II. សេចក្តីសន្និដ្ឋានបឋម

### សិទ្ធិ

6. សហមេធាវីបានលើកឡើងថា នេះគឺជាបណ្តឹងឧទ្ធរណ៍របស់ [redacted] *តាមរយៈសហមេធាវីរបស់គាត់* [16]។ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា សហមេធាវីត្រូវបានជ្រើសរើសដោយ [redacted] នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១២ ដើម្បីធ្វើជាតំណាងឱ្យរូបគាត់[17]។ ដូច្នេះ អនុលោមតាម *សម្បថវិជ្ជាជីវៈរបស់ពួកគាត់* និង *ដោយគ្មានការចេញដីកាបង្គាប់ជំទាស់ណាមួយ* ពី អ.វ.ត.ក នោះ

---

[15] ដូចយោងខាងលើ កថាខណ្ឌ ៣ និង ៤។ សារណាទាំង១៤នោះ ត្រូវបានដាក់ចូលទៅក្នុងសំណុំរឿង ០០៣ ជាឯកសារភ្ជាប់ទៅនឹងបណ្តឹងឧទ្ធរណ៍ នៅថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៤។ សូមមើលអ៊ីម៉ែលពីមន្ត្រីគ្រប់គ្រងសំណុំរឿងដែលមានកម្មវត្ថុ៖ "ឯកសារថ្មី៖ សំណុំរឿងលេខ ០០៣ បណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងការបដិសេធតាមការសន្មតរបស់សហចៅក្រមស៊ើបអង្កេតទៅលើ [សារណា] របស់ [redacted]" ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៤។

[16] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ សេចក្តីផ្តើម ។ សហមេធាវីក៏បានបញ្ជាក់ផងដែរថា សារណាពាក់ព័ន្ធទាំង១៤នេះ ត្រូវបានរៀបចំដោយផ្អែកលើការណែនាំរបស់លោក [redacted] ដើម្បីការការពារក្តីដ៏រឹងមាំ និងឋិតថេរ ហើយថា ការណែនាំទាំងអស់នេះត្រូវបានផ្តល់ជូនទៅសហមេធាវីការពារក្តី ជាថ្នូរនឹងការជ្រើសរើសពួកគេឱ្យធ្វើជាមេធាវីការពារក្តី និងត្រូវបានផ្តល់ជូន *នៅមុខ* លោកសហចៅក្រមស៊ើបអង្កេត *ហាមប្រាមមិនឱ្យមានការប្រាស្រ័យទាក់ទងគ្នា* (បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤៩)។

[17] ឯកសារ D56/13 កថាខណ្ឌ ១ យោងទៅលើ "ទម្រង់៧"។

សហមេធាវីត្រូវ *"ការពាររឿងក្ដីរហូតដល់ទីបញ្ចប់"*[18]។ អង្គបុរេជំនុំជម្រះយល់ឃើញថា សេចក្ដីសម្រេច និងដីកាកំណត់កាលបរិច្ឆេទរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៣ ដែល *បានផ្ដាក់ការប្រាស្រ័យទាក់ទង* រវាងសហមេធាវី និង [redacted] និង*បានពន្យារពេល* សម្រេចលើការតែងតាំងពួកគាត់ ដោយសារតែ*ការចោទប្រកាន់*អំពីទំនាស់ផលប្រយោជន៍ដែលបានលើកឡើងដោយសហព្រះរាជអាជ្ញា[19] មិនមែនជាដីការបស់ អ.វ.ត.ក ដែលពិតជារាំងសហមេធាវីមិនឱ្យអាច *ការពាររឿងក្ដី* ក្នុងនាម [redacted] នោះឡើយ។ ទោះបីជា ពួកគាត់*មិនអាចប្រាស្រ័យទាក់ទងជាមួយនឹង* [redacted] ក៏ដោយ ក៏*សិទ្ធិ ឬភាពសមស្រប* របស់សហមេធាវីក្នុងការការពារក្ដី [redacted] *នៅក្នុងអំឡុងពេលដែលជាកម្មវត្ថុនៃបណ្ដឹងឧទ្ធរណ៍នេះ* ពោលគឺចាប់ពីថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៣ នៅពេលសារណាដំបូងត្រូវបានដាក់ រហូតដល់ថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣ នៅពេលបណ្ដឹងឧទ្ធរណ៍នេះត្រូវបានដាក់ *មិនទាន់ត្រូវបានដកហូតដោយសហចៅក្រមស៊ើបអង្កេតនៅឡើយទេ*[20]។ នៅពេលបច្ចុប្បន្ននេះ *សិទ្ធិរបស់សហមេធាវីក្នុងការការពារក្ដី* [redacted] *តាមភាពជាក់ស្ដែងនៅតែត្រូវ* រងការជំទាស់នៅឡើយ (មិនមែនមានន័យថា ត្រូវបានដកហូតនោះទេ) ដោយផ្អែកលើមូលដ្ឋាននៃទំនាស់ផលប្រយោជន៍ រហូតដល់ពេល អ.វ.ត.ក សម្រេច *ជាស្ថាពរ* ផ្សេងពីនេះ។ ដោយពិចារណាទៅលើអង្គហេតុខាងក្រោមនេះ ៖

១) ដែលថា ដីកាសម្រេចពាក់ព័ន្ធនឹងទំនាស់របស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៤ ក៏ត្រូវបានរងការជំទាស់ផងដែរនោះ ដោយការដាក់ឯកសារ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៤ ស្ដីពីការជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍ និងនៅថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៤ ស្ដីពីបណ្ដឹងឧទ្ធរណ៍ ពាក់ព័ន្ធនឹងសេចក្ដីសម្រេចបែបនេះ[21]។

២) ដែលថា ចាប់ពីថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១២ ហើយរហូតមកដល់ពេលនេះ ពុំមានការបញ្ជាក់ពី [redacted] ថា គាត់មិនចង់ឱ្យសហមេធាវីធ្វើជាតំណាងឱ្យ

[18] បទបញ្ជារដ្ឋបាលរបស់ អ.គ.ក មាត្រា ៧.១។

[19] សេចក្ដីសម្រេច និងដីកាកំណត់កាលបរិច្ឆេទពាក់ព័ន្ធសំណើសុំតែងតាំងសហមេធាវីចាត់តាំង ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៣។

[20] សូមមើល បទបញ្ជារដ្ឋបាលរបស់ អ.គ.ក មាត្រា ៧.៤។ កត់សម្គាល់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានយល់ស្របតាមការចោទប្រកាន់របស់សហព្រះរាជអាជ្ញាតែ*នៅពេលក្រោយមកទៀត*ប៉ុណ្ណោះ គឺនៅពេលចេញសេចក្ដីសម្រេចពាក់ព័ន្ធនឹងទំនាស់ នៅថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៤។

[21] សូមមើល ឯកសារ D56/19។

គាត់ឡើយ ប៉ុន្តែតាមពិតទៅ គាត់បានបញ្ជាក់ឡើងវិញថា គាត់ចង់ឱ្យសហមេធាវីធ្វើជាតំណាងឱ្យគាត់[22] និង

៣) ដែលថា មានការសន្មតថា សហមេធាវីកំពុងតែធ្វើជាតំណាង អនុលោមតាមសម្បថវិជ្ជាជីវៈ និងកាតព្វកិច្ចតាមផ្លូវច្បាប់របស់ពួកគាត់ រហូតដល់បញ្ហាទំនាស់នេះត្រូវបានសម្រេចជាស្ថាពរ។

*ដោយមិនប៉ះពាល់ដល់សេចក្តីសម្រេចនាពេលខាងមុខ ទៅលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចពាក់ព័ន្ធនឹងទំនាស់* អង្គបុរេជំនុំជម្រះយល់ឃើញថា ពុំមានបញ្ហាសិទ្ធិឡើយ ទាក់ទិនទៅនឹងសិទ្ធិ និងលទ្ធភាពក្នុងការធ្វើជាតំណាងឱ្យ [redacted] នៅចំពោះមុខអង្គបុរេជំនុំជម្រះ សម្រាប់គោលបំណងនៃបណ្តឹងឧទ្ធរណ៍នេះ។

**សំណើសុំឱ្យមានសវនាការ**[23]

7. វិធាន ៧៧(៣)(ខ) ចែងថា "បន្ទាប់ពីបានពិចារណាលើការយល់ឃើញរបស់ភាគី អង្គបុរេជំនុំជម្រះអាចសម្រេចលើបណ្តឹងឧទ្ធរណ៍ ឬពាក្យសុំ ដោយផ្អែកតែលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ភាគីតែប៉ុណ្ណោះ"។ ដោយបានពិចារណាទៅលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរយ៉ាងច្រើនដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍ និងដោយពុំមានការដាក់ចម្លើយតបណាមួយពីសហព្រះរាជអាជ្ញា ឬដើមបណ្តឹងរដ្ឋប្បវេណីទេនោះ អង្គបុរេជំនុំជម្រះយល់ឃើញថា មិនចាំបាច់ស្តាប់ទឡ្ហីករណ៍ដោយផ្ទាល់មាត់ឡើយ នៅក្នុងករណីនេះ។

## III. **ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍**

8. សហមេធាវីស្នើសុំឱ្យអង្គបុរេជំនុំជម្រះទទួលយកបណ្តឹងឧទ្ធរណ៍ និងបង្គាប់ឱ្យសហចៅក្រមស៊ើបអង្កេតពិចារណា និងសម្រេចលើសារណាទាំងដប់បួននោះ[24]។ សហមេធាវីលើកឡើងថា បណ្តឹងឧទ្ធរណ៍ អាចទទួលយកបាន ពីព្រោះ ៖ ១) ការបដិសេធតាមការសន្មត របស់សហចៅក្រមស៊ើប

[22] ផ្ទុយទៅវិញ មានការកត់សម្គាល់ថា នៅត្រឹមថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០១៤ [redacted] បានបញ្ជាក់សារជាថ្មីអំពីគោលបំណងរបស់គាត់ចង់ឱ្យសហមេធាវីធ្វើជាតំណាងឱ្យគាត់។ សូមមើល ឯកសារ D56/19/13.1។

[23] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ សេចក្តីផ្តើម។

[24] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៥៣។

អង្កេតទៅលើសារណាមួយចំនួន ក្នុងចំណោមសារណាចំនួន ១៤ រំលោភលើសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ដែលត្រូវបានការពារ អនុលោមតាម *វិធាន ២១ នៃវិធានផ្ទៃក្នុង*[25] និង ២) សារណាមួយចំនួនទៀត ក្នុងចំណោមសារណាទាំង ១៤ គឺជាសំណើសុំឱ្យចាត់ការស៊ើបអង្កេត ដូច្នេះហើយបណ្តឹងឧទ្ធរណ៍ក៏អាចទទួលយកបានផងដែរ អនុលោមតាម *វិធាន ៧៤(៣)(ខ) នៃ វិធានផ្ទៃក្នុង*[26]។

9. សហមេធាវីលើកឡើងថា បណ្តឹងឧទ្ធរណ៍នេះគឺជាការចាំបាច់ ដោយសារតែលិខិតរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិចុះថ្ងៃទី ២៥ និងថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៣ ជូនដំណឹងដល់ពួកគាត់ថា "គាត់នឹងមិនធ្វើការសម្រេចទៅលើសារណា ដែលមិនទាន់សម្រេចសេចក្តីរបស់ [redacted] ទេ រហូតដល់ពេលដែលគាត់ចេញសេចក្តីសម្រេចទៅលើបញ្ហាទំនាស់ផលប្រយោជន៍ដែលត្រូវបានចោទប្រកាន់សិន"[27]។ ដោយយល់ឃើញថា "មិនដឹងថានៅពេលណាដែល ក.ស.ច.ស នឹងសម្រេចលើការចោទប្រកាន់អំពីទំនាស់ផលប្រយោជន៍នោះ"[28] សហមេធាវីលើកឡើងថា ត្រូវតែមានការសម្រេចទៅលើសារណាទាំងដប់បួននោះ ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន "*ដោយមិនគិតថាតើ ចុងក្រោយនរណាតំណាងឱ្យលោក* [redacted] *នោះឡើយ*"[29] ហើយថា ការខកខានមិនបានសម្រេចទៅលើសារណាទាំងនេះ នឹងធ្វើឱ្យ [redacted] បាត់បង់"លទ្ធភាពទទួលបានផលប្រយោជន៍ដែលគាត់ចង់បាន" តាមរយៈសារណាទាំងនេះ[30]។ សហមេធាវីក៏កត់សម្គាល់ផងដែរថា សហចៅក្រមស៊ើបអង្កេត *មិនបានផ្តល់មូលដ្ឋានច្បាប់ ឬហេតុផលណាមួយ* ចំពោះសេចក្តីសម្រេចពន្យារពេលក្នុងការចេញសេចក្តីសម្រេចលើសារណាទាំងនោះឡើយ[31]។

10. អង្គបុរេជំនុំជម្រះជាបឋមបានពិចារណាទៅលើទស្សនទាននៃការបដិសេធតាមការសន្មត នៅក្នុងសេចក្តីសម្រេចខែ កក្កដា ឆ្នាំ ២០០៨ ដែលនៅពេលនោះអង្គបុរេជំនុំជម្រះបានបញ្ជាក់ថា គេអាចប្តឹងឧទ្ធរណ៍បានចំពោះការខកខានរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការសម្រេចទៅលើសំណើ

---

[25] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៣ និង ៣២-៣៥។

[26] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៣ និង ៣៦។

[27] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ សេចក្តីផ្តើម។

[28] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៥។

[29] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៩។

[30] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៤ និង ២៥។

[31] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤៤។

ដោយសារទង្វើរបស់សហចៅក្រមស៊ើបអង្កេត អាចត្រូវបានបកស្រាយថាជាការបដិសេធសំណើតាមការសន្មត[32]។ អង្គបុរេជំនុំជម្រះបានបញ្ជាក់ថា ការខកខានរបស់សហចៅក្រមស៊ើបអង្កេតក្នុងការសម្រេចទៅលើសំណើ "ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន *នៅក្នុងកាលៈទេសៈ* ដែលការពន្យារពេលក្នុងការធ្វើសេចក្តីសម្រេច *នាំឱ្យជនត្រូវចោទបាត់បង់លទ្ធភាពទទួលបានផលប្រយោជន៍ដែលគាត់ចង់បាន* គឺជាការបដិសេធពាក្យសុំតាមការសន្មត *ដែលអាចប្តឹងឧទ្ធរណ៍បានអនុលោមតាមវិធាន ៧៤(៣) នៃវិធានផ្ទៃក្នុង ដែលចែងថា សំណើត្រូវបានអនុញ្ញាត អនុលោមតាមវិធានផ្ទៃក្នុង*[33]។ ពាក់ព័ន្ធនឹងសំណើ *ដែលមិនត្រូវបានអនុញ្ញាត* អនុលោមតាមវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះបានលើកឡើងថា វាជាការមិនត្រឹមត្រូវទេ ក្នុងការប្រើប្រាស់ការបដិសេធតាមការសន្មតជាមូលដ្ឋានសម្រាប់បណ្តឹងឧទ្ធរណ៍ចំពោះសំណើដែលមិនត្រូវបានបំពេញ ឬដែលត្រូវបានបដិសេធ[34]។ ប៉ុន្តែ ទាក់ទិននឹងបណ្តឹងឧទ្ធរណ៍ជាក់លាក់មួយចំនួន ដែលបានដាក់ប្រឆាំងនឹងការបដិសេធតាមការសន្មតទៅលើ*សំណើដែលមិនត្រូវបានអនុញ្ញាតឱ្យបានច្បាស់លាស់ អនុលោមតាមវិធានផ្ទៃក្នុង ប៉ុន្តែអាចពាក់ព័ន្ធនឹងសិទ្ធិជាមូលដ្ឋានរបស់ភាគីនោះ* អង្គបុរេជំនុំជម្រះបានពិចារណាពិនិត្យថាតើ *វិធាន ២១ នៃវិធានផ្ទៃក្នុង* តម្រូវ ឬមិនតម្រូវឱ្យអង្គជំនុំជម្រះបកស្រាយទូលាយ អំពីសិទ្ធិប្តឹងឧទ្ធរណ៍របស់ [...] ដើម្បីធានាឱ្យដំណើរការនីតិវិធីមានភាពយុត្តិធម៌ និងបានការពារដល់សិទ្ធិរបស់ [...][35]។ អង្គបុរេជំនុំជម្រះបានលើកឡើងថា *ការស៊ើបអង្កេតរបស់សហចៅក្រមស៊ើប*

---

[32] សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ ដែលបានសម្រេចផ្ទាល់មាត់នៅថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៨ អំពីសំណើសុំពន្យារពេលសវនាការលើបញ្ហាយុត្តាធិការរបស់សហមេធាវីការពារក្តី ថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០០៨ ឯកសារ C22/I/49 កថាខណ្ឌ ៥។

[33] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ទាក់ទងនឹងការចាត់តាំងអ្នកជំនាញផ្នែកចិត្តសាស្ត្រ ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៨ ឯកសារ A189/I/8 កថាខណ្ឌ ១៤-២៤។ នៅក្នុងករណីពិសេសនេះ អង្គបុរេជំនុំជម្រះគួសបញ្ជាក់ថា សំណើនេះ ត្រូវបានអនុញ្ញាត អនុលោមតាមវិធានផ្ទៃក្នុង (វិធាន ៣០(១០) នៃវិធានផ្ទៃក្នុង) ហើយថា តាមលក្ខណៈរបស់វា និងដោយយោងទៅលើពេលវេលាកំណត់ជាក់លាក់ដែលមានចែងនៅក្នុងមាត្រា ១៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា សំណើសុំនេះ តម្រូវឱ្យយកចិត្តទុកដាក់ឱ្យបានទាន់ពេលវេលា។

[34] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការបដិសេធតាមការសន្មតរបស់សហចៅក្រមស៊ើបអង្កេតទៅលើសំណើលើកទី៣ របស់ អៀង សារី សុំឱ្យបំពេញកិច្ចស៊ើបសួរ ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០០៩ ឯកសារ D171/4/5 កថាខណ្ឌ ៩។

[35] សាលដីកាសម្រេចលើការទទួលយកបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងការបដិសេធតាមការសន្មតរបស់ ក.ស.ច.ស លើសំណើរបស់លោក អៀង សារី ទាក់ទងនឹងការទទួលស្គាល់របស់ ក.ស.ច.ស នូវភស្តុតាង និងការសំអាងទៅលើភស្តុតាងដែលទទួលបានតាមរយៈការធ្វើទារុណកម្ម ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១០ ឯកសារ D130/7/3/5 កថាខណ្ឌ ២៨។

*អង្កេត ត្រូវបានធ្វើឡើងដោយឯករាជ្យ* ហើយថា អង្គបុរេជំនុំជម្រះនឹងមិនកំណត់អំពី "វិធីសាស្ត្រ ឬលក្ខណៈនៃការស៊ើបអង្កេត ដែលស្ថិតនៅក្នុងអំណាចឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតឡើយ លើកលែងតែ និងលុះត្រាតែអង្គបុរេជំនុំជម្រះយល់ឃើញថា កិច្ចស៊ើបសួរជះឥទ្ធិពលដល់*ដំណើរការត្រឹមត្រូវ ឬសិទ្ធិផ្សេងៗទៀត* "[36]។ នៅក្នុងករណីខាងក្រោមនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា អង្គជំនុំជម្រះនឹងមិនជ្រៀតជ្រែកទៅក្នុងឆន្ទានុសិទ្ធិ ក្នុងការធ្វើសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតឡើយ៖ (i) នៅពេលដែលសហចៅក្រមស៊ើបអង្កេតបានចាត់វិធានការគ្រប់គ្រាន់ក្នុងការបន្តកិច្ចស៊ើបសួរ ប៉ុន្តែពុំទទួលបានជោគជ័យក្នុងការបំពេញទៅតាមសំណើ[37] (ii) នៅពេលដែលវិធានផ្ទៃក្នុង មិនចងកាតព្វកិច្ចសហចៅក្រមស៊ើបអង្កេតឱ្យសម្រេចលើបញ្ហាមួយមុនពេលវេលាជាក់លាក់ណាមួយ ប៉ុន្តែនឹងមានការចេញសេចក្តីសម្រេចបែបនេះ ក្នុងពេលឆាប់ៗខាងមុខ[38] (iii) នៅពេលដែល "សំណើទាំងនោះមិនមែនជាសំណើសុំឱ្យមានកិច្ចស៊ើបសួរ នៅក្នុងវិសាលភាពវិធាន ៧៥(៣) នៃវិធានផ្ទៃក្នុង ដោយពិចារណាលើគោលបំណងរបស់ពួកគាត់[39] និង (iv) នៅពេលដែលសិទ្ធិជាមូលដ្ឋានដែលមានចែងនៅក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង ត្រូវបានការពារយ៉ាងគ្រប់គ្រាន់ ដោយក្របខណ្ឌច្បាប់ជាធរមាន[40]។

11. ឥឡូវនេះ អង្គបុរេជំនុំជម្រះងាកមកផ្តោតទៅលើទឡ្ហីករណ៍ផ្សេងៗ នៃភាពអាចទទួលយកបានដែលមាននៅក្នុងបណ្តឹងឧទ្ធរណ៍ និងទៅលើសារណានីមួយៗក្នុងចំណោមសារណាទាំង ១៤ ដែល

---

[36] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ ក.ស.ច.ស ចំពោះសំណើសុំ D153, D172, D173, D174, D178 & D284 (សំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ១២ របស់ នួន ជា) ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០១០ ឯកសារ D300/1/5 កថាខណ្ឌ ២២។

[37] សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងការបដិសេធតាមការសន្និដ្ឋានលើសំណើលើកទីប្រាំពីរ សុំបំពេញកិច្ចស៊ើបសួរ ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៩ ឯកសារ D122/4/3 កថាខណ្ឌ

[38] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចលើសំណើរបស់លោក អៀង សារី ប្រឆាំងនឹងការអនុវត្តទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារ D345/5/11 កថាខណ្ឌ ១១។

[39] សាលដីកាសម្រេចលើការទទួលយកបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងការបដិសេធតាមការសន្និដ្ឋានរបស់ ក.ស.ច.ស លើសំណើរបស់លោក អៀង សារី ទាក់ទងនឹងការទទួលស្គាល់របស់ ក.ស.ច.ស នូវភស្តុតាង និងការសំអាងទៅលើភស្តុតាងដែលទទួលបានតាមរយៈការធ្វើទារុណកម្ម ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១០ ឯកសារ D130/7/3/5 កថាខណ្ឌ ២៣-២៤។

[40] ដូចយោងខាងលើ កថាខណ្ឌ ២៦-៣០។

ពាក់ព័ន្ធ។ អង្គបុរេជំនុំជម្រះសូមកត់សំគាល់ថា បើទោះជាមានការសង្កេតជាច្រើនខាងក្រោម អង្គបុរេជំនុំជម្រះយល់ឃើញថា ដើម្បីចាត់ទុកបញ្ហាមួយថា អាចត្រូវប្តឹងឧទ្ធរណ៍បានដោយផ្អែកតែទៅលើការបដិសេធតាមការសន្មតមួយប៉ុណ្ណោះ រយៈពេលកន្លងមកត្រូវតែមានចំនួនលើសពីរយៈពេលសមហេតុផលចាប់ពីពេលសំណើត្រូវបានដាក់។ ចំពោះបញ្ហាទាំងអស់ដែលកំពុងមាននៅចំពោះមុខអង្គបុរេជំនុំជម្រះ លើកលែងតែចំពោះសំណើសុំចូលពិនិត្យមើលសំណុំរឿងមួយចេញ រយៈពេលកន្លងមកមិនមានចំនួនលើសពីរយៈពេលសមហេតុផលឡើយ។ បើទោះជាបែបនេះក្តី ជាការត្រឹមត្រូវក្នុងការដោះស្រាយសំណើនីមួយៗ ពាក់ព័ន្ធនឹងមូលដ្ឋានច្បាប់នៃសំណើចំពោះការទាមទារសិទ្ធិទទួលបានដំណោះស្រាយ អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង។

**សំណើសុំចូលពិនិត្យមើលសំណុំរឿង និងសំណើសុំចូលរួមក្នុងការស៊ើបអង្កេត**[41]

12. សហមេធាវីលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍ថា សំណើរបស់ [redacted] ស្នើសុំការអនុញ្ញាតចូលពិនិត្យមើលសំណុំរឿង និងចូលរួមក្នុងការស៊ើបអង្កេតតាមផ្លូវតុលាការ "មានសារៈសំខាន់ណាស់ក្នុងការគោរពសិទ្ធិរបស់លោក [redacted] *ក្នុងការទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីត្រៀមរៀបចំការពារក្តីរបស់គាត់*"[42] ហើយថា វិធាន ២១ នៃវិធានផ្ទៃក្នុង "តម្រូវឱ្យមានការទទួលយកបណ្តឹងឧទ្ធរណ៍ ដើម្បីការពារ [*ក្នុងចំណោមប្រការផ្សេងទៀត* សិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌] និងដើម្បីធានានូវភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី"[43]។

13. ដោយមិនប៉ះពាល់ដល់ឋានៈរបស់ [redacted] នៅក្នុងកិច្ចដំណើរការនីតិវិធីស៊ើបអង្កេត ដោយពិចារណាថា៖

ក. ប្រសិនបើឋានៈរបស់បុគ្គលនៅក្នុងការស៊ើបអង្កេត អនុញ្ញាតឱ្យមានការពិនិត្យមើលសំណុំរឿងនោះ វិធានផ្ទៃក្នុងអនុញ្ញាតឱ្យចូលពិនិត្យមើលសំណុំរឿងតាមរយៈមេធាវីតែប៉ុណ្ណោះ ហើយថា

[41] សំណើរបស់ [redacted] ស្នើសុំការអនុញ្ញាតចូលពិនិត្យសំណុំរឿង និងចូលរួមក្នុងការស៊ើបអង្កេតតាមផ្លូវតុលាការ ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ D82។

[42] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៩(ក)។

[43] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២១(ក) និង(ខ)។ សូមមើលផងដែរ ឯកសារ D82 កថាខណ្ឌ សេចក្តីផ្តើម។

ខ. សហមេធាវីរបស់ [redacted] នៅពេលនេះ កំពុងតែជំទាស់ទៅនឹងសេចក្ដីសម្រេច ពាក់ព័ន្ធនឹងទំនាស់នោះ

អង្គបុរេជំនុំជម្រះយល់ឃើញថា ជាការសមស្របក្នុងការពន្យារការសម្រេច ទៅលើបណ្ដឹងឧទ្ធរណ៍ ទាក់ទិននឹងសំណើសុំចូលពិនិត្យមើលសំណុំរឿង រហូតដល់ពេលអង្គជំនុំជម្រះសម្រេចទៅលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្ដីសម្រេចពាក់ព័ន្ធនឹងទំនាស់។

**សំណើសុំព័ត៌មាន ពាក់ព័ន្ធនឹងរបៀប និងវិធីសាស្ត្រស៊ើបអង្កេតរបស់ ក.ស.ច.ស**[44]

14. សហមេធាវីលើកឡើងនៅក្នុងបណ្ដឹងឧទ្ធរណ៍ថា សំណើសុំព័ត៌មានពាក់ព័ន្ធនឹងរបៀប និងវិធីសាស្ត្រស៊ើបអង្កេត “ធ្វើឡើងជាការចាំបាច់ ពីព្រោះវាមិនអាចវិនិច្ឆ័យបានថាតើ *កិច្ចស៊ើបសួរដ៏ហ្មត់ចត់ ដោយយកចិត្តទុកដាក់ និងប្រកបដោយយុត្តិធម៌ កំពុងត្រូវបានអនុវត្តឬយ៉ាងណា* និងថាតើមានវិធីសាស្ត្រស៊ើបអង្កេតដូចគ្នាសម្រាប់អនុវត្តដែរឬទេ (ឧទាហរណ៍ បែបបទដែលមានភាពយុត្តិធម៌ ស៊ីសង្វាក់គ្នា និងមានតម្លាភាព) ហើយប្រសិនបើមាន តើអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស កំពុងតែអនុវត្តតាមវិធីសាស្ត្រនេះដោយយកចិត្តទុកដាក់ដែរឬទេ”[45]។ សហមេធាវីស្នើឡើងថា ទាក់ទិននឹងសំណើនេះ *វិធាន ២១ នៃវិធានផ្ទៃក្នុង* តម្រូវឱ្យមានការទទួលយកបណ្ដឹងឧទ្ធរណ៍ ដើម្បីការពារសិទ្ធិរបស់លោក [redacted] *ក្នុងការទទួលបានការស៊ើបអង្កេតដោយយុត្តិធម៌ ឯករាជ្យ និងដោយមិនលម្អៀង*[46]។

15. អង្គបុរេជំនុំជម្រះបានបញ្ជាក់ថា ការស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេត ត្រូវបានធ្វើឡើងដោយឯករាជ្យ ហើយថា អង្គបុរេជំនុំជម្រះនឹងមិនធ្វើការកំណត់ “វិធីសាស្ត្រ ឬលក្ខណៈនៃការស៊ើបអង្កេត ដែលស្ថិតនៅក្នុងអំណាចឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតឡើយ លើកលែងតែ និងលុះត្រាតែអង្គបុរេជំនុំជម្រះយល់ឃើញថា កិច្ចស៊ើបសួរជះឥទ្ធិពលដល់*ដំណើរការត្រឹមត្រូវ ឬសិទ្ធិផ្សេងៗទៀត*របស់ជនត្រូវចោទ។ វាជាការមិនត្រឹមត្រូវឡើយ ក្នុងការពង្រីកទស្សនទាននៃការបដិសេធតាមការសន្មត ដើម្បីអាចឱ្យអង្គបុរេជំនុំជម្រះពិនិត្យពិច័យទៅលើភាពគ្រប់គ្រាន់នៃ

[44] សំណើសុំព័ត៌មាន ពាក់ព័ន្ធនឹងរបៀប និងវិធីសាស្ត្រស៊ើបអង្កេតរបស់ ក.ស.ច.ស ថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D87/2/1.3។

[45] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ១៩(ខ)។ សូមមើលផងដែរ ឯកសារ D87/2/1.3 កថាខណ្ឌ ២៩, ៣៥, ៣៨ និង ៤៨។

[46] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ២៣។ សូមមើលផងដែរ ឯកសារ D87/2/1.3 កថាខណ្ឌ សេចក្ដីផ្ដើម *ដែលយោងទៅលើ*[illegible] ២១ នៃវិធានផ្ទៃក្នុង។

ការបំពេញកិច្ចស៊ើបសួររបស់ [សហចៅក្រមស៊ើបអង្កេត] ដូច្នេះ ការពង្រីកទស្សនទាននោះ នឹងធ្វើឱ្យអង្គជំនុំជម្រះនេះ រំលោភទៅលើឆន្ទានុសិទ្ធិក្នុងការស៊ើបអង្កេតដែលត្រូវប្រគល់ឱ្យ [សហចៅក្រមស៊ើបអង្កេត] ដោយវិធានផ្ទៃក្នុង ៥៥(៥)"[47]។ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា នៅក្នុងសំណើនេះ សហមេធាវីមិនបានចង្អុលបង្ហាញអំពី "កិច្ចស៊ើបសួរណា" ដែលអាចប៉ះពាល់ដល់សិទ្ធិរបស់ [redacted] ប៉ុន្តែពួកគាត់បែរជាស្នើសុំព័ត៌មានអំពីលក្ខណៈទូទៅស្តីអំពីវិធីសាស្ត្រក្នុងការស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេត។ ដូច្នេះ សំណើនេះធ្វើឱ្យបណ្តឹងឧទ្ធរណ៍មិនអាចត្រូវបានទទួលយកបាន ដោយផ្អែកមូលដ្ឋានទៅលើការបដិសេធតាមការសន្មតឡើយ ឬទៅលើការអះអាងដែលថាសិទ្ធិជាមូលដ្ឋានត្រូវបានពង្វាងចេញពីវិធាន២១ នៃវិធានផ្ទៃក្នុងនោះ។

**សំណើសុំមិនឱ្យមានការចូលរួមពី Stephen Heder[48] និង David Boyle[49]**

16. សហមេធាវីលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍ថា "សំណើនេះធ្វើឡើងជាការចាំបាច់ ដោយសារលោក [redacted] មានសិទ្ធិទទួលបានកិច្ចស៊ើបសួរមួយ*ប្រកបដោយយុត្តិធម៌ និងមានភាពអនាគតិ*"[50]។ នៅក្នុងសំណើទាំងនេះ សហមេធាវីចោទប្រកាន់ថា លោក Heder និងលោក Boyle មាន *ភាពលម្អៀង* ហើយថា ការចូលរួមណាមួយរបស់ពួកគាត់ក្នុងតួនាទីណាក៏ដោយ នឹងប៉ះពាល់ដល់កិច្ចស៊ើបសួរនេះមិនខាន។ សហមេធាវីបញ្ជាក់ថា សំណើទាំងនេះធ្វើឡើងជាការចាំបាច់ ព្រោះថា ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន*ដោយយកចិត្តទុកដាក់* មេធាវីការពារក្តីត្រូវពិនិត្យឡើងវិញទៅលើលទ្ធផលការងាររបស់លោក Heder និងលោក Boyle *ដើម្បីសម្រេចថា តើចាំបាច់ត្រូវ*

---

[47] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ ក.ស.ច.ស ចំពោះសំណើសុំ D153, D172, D173, D174, D178 & D284 (សំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ១២ របស់ នួន ជា) ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០១០ ឯកសារ D300/1/5 កថាខណ្ឌ ២២។

[48] សេចក្តីជូនដំណឹងរបស់លោក [redacted] ពីការជំទាស់ទៅនឹងការចូលរួម ពាក់ព័ន្ធបន្ថែមទៀត របស់លោក STEPHEN HEDER នៅក្នុងសំណុំរឿង ០០៣ និង សំណើសុំលទ្ធផលការងារ របស់លោក STEPHEN HEDER ថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D87/2/1.4។

[49] សេចក្តីជូនដំណឹងរបស់លោក [redacted] ពីការជំទាស់ទៅនឹងការចូលរួម ពាក់ព័ន្ធបន្ថែមទៀត របស់លោក David Boyle នៅក្នុងសំណុំរឿង ០០៣ និង សំណើសុំលទ្ធផលការងារ របស់លោក David Boyle ថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D87/2/1.5។

[50] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៩(គ) និង (ឃ)។

*ដាក់ពាក្យសុំមោឃភាពការបំពេញកិច្ចស៊ើបសួរ* អនុលោមតាមវិធាន ៧៦ ឬយ៉ាងណា”[51]។ សហមេធាវីស្នើឡើងថា ទាក់ទិននឹងសំណើនេះ *វិធាន ២១ នៃវិធានផ្ទៃក្នុង* តម្រូវឱ្យមានការទទួលយកបណ្ដឹងឧទ្ធរណ៍ ដើម្បីការពារសិទ្ធិរបស់លោក [redacted] *ក្នុងការទទួលបានការស៊ើបអង្កេតដោយយុត្តិធម៌ ឯករាជ្យ និងដោយមិនលម្អៀង* [52]។

17. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា នៅក្នុងសំណើទាំងនេះ សហមេធាវីជំទាស់ទៅនឹងភាពត្រឹមត្រូវនៃការស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេត ដោយចោទប្រកាន់អំពីភាពលម្អៀងរបស់*បុគ្គលិក* ហើយផ្អែកទៅលើមូលដ្ឋានទាំងនោះ សហមេធាវីស្នើឡើងថា ការពិនិត្យមើលទៅលើលទ្ធផលការងាររបស់បុគ្គលិកទាំងនោះ គឺជាការចាំបាច់ ពីព្រោះវា*អាច* ត្រូវបានរកឃើញថា មានភាពមិនប្រក្រតី ឬមិនត្រឹមត្រូវ ដែលតម្រូវឱ្យមោឃភាពចោល។ ទាក់ទិនទៅនឹងលោក Heder ការចោទប្រកាន់អំពីភាពលម្អៀង ត្រូវបានផ្អែកទៅលើ*អត្ថបទនានា* ដែលគាត់បានបោះពុម្ពផ្សាយទៅលើជម្រើសផ្ទាល់ខ្លួនគាត់នាពេលថ្មីៗនេះ ចំពោះថាតើត្រូវបន្តបំពេញការងារឱ្យ ក.ស.ច.ស ឬថាតើត្រូវផ្ដល់សក្ខីកម្មក្នុងសវនាការក្នុងសំណុំរឿង ០០២ ឬយ៉ាងណា។ គាត់គឺជា “ទីប្រឹក្សារបស់មជ្ឈមណ្ឌលឯកសារកម្ពុជា” និង“ត្រូវបានគេអះអាងថា គាត់កំពុងតែបម្រើការងារឱ្យអង្គការឃ្លាំមើលសិទ្ធិមនុស្ស ក្នុងតួនាទីជាអ្នកស្រាវជ្រាវ”[53]។ ទាក់ទិនទៅនឹងលោក Boyle ការចោទប្រកាន់អំពីភាពលម្អៀង ត្រូវបានផ្អែកទៅលើអត្ថបទនានា ដែលគាត់បានបោះពុម្ពផ្សាយ និងទៅលើទស្សនៈផ្ទាល់ខ្លួនរបស់គាត់ ស្ដីអំពីរបៀបដែលតុលាការគួរបំពេញការងារ[54]។

18. ជាដំបូង អង្គបុរេជំនុំជម្រះសង្កេតឃើញថា សំណើទាំងនេះ រួមទាំងឯកសារយោងផ្សេងៗអំពីសកម្មភាពថ្មីៗបំផុតរបស់លោក Heder និងលោក Boyle ជាសំណើច្រំដែលជាន់គ្នាទៅលើសំណើមុនៗ ដែលសហមេធាវីដដែល នៅក្នុងសំណុំរឿង ០០២ បានដាក់ ទាក់ទិននឹងបុគ្គលិកដដែលទាំងនេះ[55]។ អង្គបុរេជំនុំជម្រះធ្លាប់បានបញ្ជាក់រួចហើយថា អង្គជំនុំជម្រះ “យល់ឃើញថា ការអះអាង

---

[51] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ១៩(គ) និង ១៩(ឃ)។

[52] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ២៣។ សូមមើលផងដែរ ឯកសារ D87/2/1.4 និងឯកសារ D87/2/1.5 កថាខណ្ឌ សេចក្ដីផ្ដើមដែលយោងទៅលើវិធាន ២១ នៃវិធានផ្ទៃក្នុង។

[53] ឯកសារ D87/2/1.4 កថាខណ្ឌ ៥-១១។

[54] ឯកសារ D87/2/1.5 កថាខណ្ឌ ១-១០។

[55] សូមមើលពាក្យសុំរបស់ អៀង សារី ស្នើសុំប្ដឹងជំទាស់អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស Stephen Header និង[illegible] របស់ ក.ស.ច.ស David Boyle នៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេត ថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ ២០០៩ [illegible]

របស់សហមេធាវីការពារក្តី មិនបានបង្ហាញអំពីអត្ថិភាពនៃកំហុសនីតិវិធី ឬការរំលោភមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនោះទេ" ថា "ចំណុចចម្បងនោះ គឺសហមេធាវីការពារក្តីបានផ្អែកពាក្យសុំរបស់ខ្លួនលើជំហររបស់ខ្លួនថា ការជ្រើសរើសបណ្ឌិត Heder និងលោក Boyle *មកបំពេញការងារ* ទាមទារឱ្យធ្វើមោឃភាពលើកិច្ចស៊ើបសួរមួយចំនួនដែលសហមេធាវី*មិនបានកំណត់* " ហើយថា "សហមេធាវីមិនបានផ្តល់ហេតុផលនៅក្នុងពាក្យសុំរបស់ខ្លួនឡើយ នៅពេលដកស្រង់យកឯកសារស្រាវជ្រាវ និងសម្ភារៈពាក់ព័ន្ធ ដើម្បីបង្កើតជាមូលដ្ឋាននៃការអះអាងអំពីភាពលម្អៀងនោះ"[56]។ ការពិចារណាចុងក្រោយរបស់អង្គបុរេជំនុំជម្រះ នៅក្នុងសេចក្តីសម្រេចនោះ ពាក់ព័ន្ធនឹងទឡ្ហីករណ៍របស់សហមេធាវីដែលបានលើកឡើងថា "បុគ្គលិករបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត"[57] ដែលត្រូវបានចោទប្រកាន់ថាមានភាពលម្អៀង កំពុងតែធ្វើឱ្យប៉ះពាល់លើកិច្ចស៊ើបសួរដែលត្រូវធ្វើឡើងដោយអនាគតិ។ ពាក់ព័ន្ធនឹងបញ្ហានេះ អង្គបុរេជំនុំជម្រះយល់ឃើញថា "ទឡ្ហីករណ៍នេះមិនមានមូលដ្ឋានឡើយ ដោយសារតែមូលហេតុស្រដៀងៗគ្នា"[58]។ អង្គបុរេជំនុំជម្រះបានសម្រេចនៅក្នុងពាក្យសុំរបស់ជនត្រូវចោទ ដែលបានស្នើសុំប្តឹងជំទាស់ បណ្ឌិត Heder និងលោក Boyle ថា៖

> "តួនាទី និងមុខងាររបស់អ្នកស៊ើបអង្កេត ឬមន្ត្រីច្បាប់ មានការបែងចែកខុសពីតួនាទី និងមុខងាររបស់សហចៅក្រមស៊ើបអង្កេត។ អនុលោមតាមកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាល ពាក់ព័ន្ធនឹងការផ្តន្ទាទោសលើបទឧក្រិដ្ឋនានា ដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ("កិច្ចព្រមព្រៀង") ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់ទោសបទឧក្រិដ្ឋនានា ដែល

---

១។ សូមមើលផងដែរ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់ ក.ស.ច.ស សម្រេចបដិសេធសំណើរបស់គាត់ សុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបសួរ ដែលធ្វើឡើងដោយ ឬដោយមានជំនួយពីលោក Stephen Heder និងលោក David Boyle និងលើសំណើរបស់លោក អៀង សារី សុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពភស្តុតាងទាំងឡាយដែលប្រមូលពីមជ្ឈមណ្ឌលឯកសារកម្ពុជា និងបណ្តឹងឧទ្ធរណ៍បន្ទាន់ប្រឆាំងនឹងការបដិសេធរបស់ ក.ស.ច.ស លើការផ្អាកកិច្ចដំណើរការនីតិវិធី ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១០ ឯកសារ D402/1/4 (សេចក្តីសម្រេចពាក់ព័ន្ធនឹងសំណើសុំមោឃភាព) ។

[56] សេចក្តីសម្រេចពាក់ព័ន្ធនឹងសំណើសុំមោឃភាព កថាខណ្ឌ ៣៣។

[57] សេចក្តីសម្រេចពាក់ព័ន្ធនឹងសំណើសុំមោឃភាព កថាខណ្ឌ ៣៥។

[58] ដូចយោងខាងលើ។

បានប្រព្រឹត្តឡើងនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ("ច្បាប់ អ.វ.ត.ក") ព្រមទាំង វិធានផ្ទៃក្នុង *សហចៅក្រមស៊ើបអង្កេតមានសិទ្ធិអំណាច និងការទទួលខុសត្រូវតែម្នាក់ឯង ប៉ុណ្ណោះក្នុងការដឹកនាំកិច្ចស៊ើបសួររបស់តុលាការ និងកំណត់សម្រេចនូវអ្វីដែលពួកគាត់ យោង*នៅក្នុងសេចក្តីសម្រេច និងដីការនានារបស់ខ្លួន។ នៅក្នុងកាលៈទេសៈទាំងនេះ ឯករាជ្យភាព និងភាពអនាគតិរបស់សហចៅក្រមស៊ើបអង្កេត *បានការពារនូវសិទ្ធិក្នុងការ ទទួលបាននូវការកាត់សេចក្តីដោយភាពយុត្តិធម៌*របស់ជនត្រូវចោទ"[59]។

អង្គហេតុដែលបង្កើតជាមូលដ្ឋាននៃសំណើពាក់ព័ន្ធនឹង Heder និង Boyle មានលក្ខណៈដដែលៗ ដូចនឹង "ការចោទប្រកាន់នៅក្នុងបណ្តឹងមិតចិត្ត"[60]។ ដោយសារមិនមានអង្គហេតុថ្មីៗទេ អង្គបុរេ ជំនុំជម្រះនឹងមិនពិចារណាលើសំណើនេះថែមទៀតទេ។

19. ទាក់ទិននឹងទឡ្ហីករណ៍របស់សហមេធាវីនៅក្នុងសំណើទាំងពីរនេះ ដែលបានលើកឡើងពីកាតព្វកិច្ច *ត្រូវយកចិត្តទុកដាក់*របស់ខ្លួន អង្គបុរេជំនុំជម្រះបញ្ជាក់ថា កាតព្វកិច្ចនេះគឺជាផ្នែកនៃសិទ្ធិក្នុងការ ត្រៀមរៀបចំការពារខ្លួន ដូចដែលបានធានានៅក្នុងមាត្រា ១៤(៣)(ខ) នៃកិតកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ដែលអាចយកមកអនុវត្តបានដោយផ្ទាល់នៅ អ.វ.ត.ក[61]។ សិទ្ធិក្នុងការត្រៀមរៀបចំការពារខ្លួន រួមមានសិទ្ធិរបស់ជនជាប់ចោទក្នុងការយល់ដឹងពី "លទ្ធផលនៃកិច្ចស៊ើបសួរ" ដូចជានៅ "ក្នុងឯកសារ និងកំណត់ត្រាទាំងឡាយក្នុងសំណុំរឿង"[62] ដែលមិនរាប់បញ្ចូលនូវសិទ្ធិទទួលបានព័ត៌មានអំពី "លទ្ធផលការងាររបស់បុគ្គលិកជាក់លាក់ណា ម្នាក់ឡើយ"។ នៅក្នុងករណីដែលលទ្ធផលការងាររបស់បុគ្គលិកជាក់លាក់ណាម្នាក់ ស្ថិតនៅក្រោម

---

[59] ដូចយោងខាងលើ។

[60] ដូចយោងខាងលើ កថាខណ្ឌ ៣៥-៣៦។

[61] កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ស្តីអំពីការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានៃឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តិឡើង ក្នុងកំឡុងពេលកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានចុះហត្ថលេខា នាថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៣ "កិច្ចព្រមព្រៀង" មាត្រា១២(២)។

[62] សាលដីកាសម្រេចលើការទទួលយកបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងការបដិសេធតាមការសន្និដ្ឋានរបស់ ក.ស.ច.ស លើសំណើរបស់លោក អៀង សារី ទាក់ទងនឹងការទទួលស្គាល់របស់ ក.ស.ច.ស នូវភស្តុតាង និងការសំអាងទៅ លើភស្តុតាងដែលទទួលបានតាមរយៈការធ្វើទារុណកម្ម ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១០ ឯកសារ D130/7/3/5 ERN 00512912-00512924 អបជ ៣១ កថាខណ្ឌ ៣១ ដែលយោងទៅលើមាត្រា ១៤(៣)(ខ) នៃ ICCPR និងទៅលើយុត្តិសាស្ត្រ ពីគណៈកម្មាធិការសិទ្ធិមនុស្ស និងតុលាការសិទ្ធិមនុស្សអឺរ៉ុប។

អត្ថន័យជា "ឯកសារ ឬកំណត់ត្រាទាំងឡាយដែលមាននៅក្នុងសំណុំរឿង" ដែលជាកំណត់ហេតុនៃការស៊ើបអង្កេត ឬរបាយការណ៍នៃការស្តាប់ចម្លើយ ដែលត្រូវបានរៀបចំឡើងតាមសេចក្តីបង្គាប់របស់សហចៅក្រមស៊ើបអង្កេតនៅក្នុងដីកាចាត់ឱ្យស៊ើបសួរជំនួសនោះ មានតែនៅពេលដែលសហមេធាវីត្រូវបានអនុញ្ញាតឱ្យចូលពិនិត្យមើលសំណុំរឿងប៉ុណ្ណោះ ដែលពួកគាត់នឹងអាចពិនិត្យមើល*កំណត់ត្រាជាក់លាក់* នៃការស៊ើបអង្កេត ហើយនៅពេលនោះ តាមរយៈខ្លឹមសារនៃឯកសារជាក់លាក់ទាំងនោះ ពួកគាត់នឹងអាចកំណត់នូវចំណុចណាដែលអាចមានលក្ខណៈមិនត្រឹមត្រូវ ឬមិនប្រក្រតី តាមការយល់ឃើញរបស់ពួកគាត់ ដែលតម្រូវឱ្យដាក់ពាក្យសុំមោឃភាព[63]។

20. អាស្រ័យហេតុនេះ ដោយយោងទៅលើហេតុផលដែលបានបញ្ជាក់ជូនខាងលើ អង្គបុរេជំនុំជម្រះយល់ឃើញថា ការយឺតយ៉ាវក្នុងការឆ្លើយតបរបស់ ក.ស.ច.ស ចំពោះសំណើទាំងនេះ មិនរារាំងអ្នកស្នើសុំមិនឱ្យទទួលបានផលប្រយោជន៍ដែលបានស្នើឡើងនោះទេ ដែលជា "ការអាចរៀបចំការស្នើសុំមោឃភាពកិច្ចស៊ើបសួរ ដោយអនុលោមតាមវិធាន ៧៦ ប្រសិនបើចាំបាច់"។ បើទោះជាមានការយឺតយ៉ាវ ក្នុងការសម្រេចទៅលើបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងសំណើសុំពិនិត្យសំណុំរឿងក្តី ក៏អង្គបុរេជំនុំជម្រះយល់ថា សំណើទាំងនេះមិនធ្វើឱ្យបណ្តឹងឧទ្ធរណ៍ត្រូវបានទទួលយក ដោយផ្អែកមូលដ្ឋានទៅលើការបដិសេធតាមការសន្មតឡើយ។

**សំណើពាក់ព័ន្ធនឹងលិខិតឆ្លើយឆ្លងពីប្រធានផ្នែកច្បាប់របស់ ក.ស.ច.ស ទៅកាន់អង្គការសហប្រជាជាតិ[64]**

21. សហមេធាវីបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍ថា "សំណើនេះមានសារៈសំខាន់ណាស់ ពីព្រោះសិទ្ធិរបស់ [redacted] ក្នុងការទទួលបាននូវការស៊ើបអង្កេត*ដោយយុត្តិធម៌ ឯករាជ្យ និងដោយមិន*

[63] ត្រង់ចំណុចនេះ អង្គបុរេជំនុំជម្រះបានបញ្ជាក់ថា នីតិវិធីមោឃភាពមិនត្រូវបានរៀបចំឡើងដើម្បីធ្វើមោឃភាពការស៊ើបអង្កេតជាទូទៅទេ ដោយសម្រាប់តែការមោឃភាពផ្នែកមួយចំនួននៃនីតិវិធីដែលប៉ះពាល់ដល់ផលប្រយោជន៍/សិទ្ធិដែលត្រូវបានកំណត់រួច។ សូមមើល សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំធ្វើមោឃភាពដោយមូលហេតុរំលោភ លើនីតិវិធី ថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០១០ ឯកសារ D197/5/8, ERN 00507486-00507495 អបជ ៣០ កថាខណ្ឌ ២៤។

[64] សំណើរបស់ [redacted] ស្នើសុំឱ្យផ្តល់ជូននូវលិខិតឆ្លើយឆ្លងពីប្រធានផ្នែកច្បាប់របស់ ក.ស.ច.ស ទៅកាន់អគ្គលេខាធិការអង្គការសហប្រជាជាតិ និងឯកសារពាក់ព័ន្ធទាំងអស់ និង ស្នើសុំឱ្យដាក់ឯកសារនេះទៅក្នុងសំណុំរឿង ថ្ងៃទី ៦ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D87/2/1.6។



E.C.C.C. • C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

*លម្អៀង* អាចត្រូវបានប៉ះពាល់ ឬអាចបន្តប៉ះពាល់ ដោយអង្គហេតុដែលថា ក្រុមអ្នកច្បាប់អន្តរជាតិរបស់ ក.ស.ច.ស បានអំពាវនាវឱ្យអង្គការសហប្រជាជាតិ "ជ្រៀតជ្រែកចូលក្នុងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត "ពាក់ព័ន្ធនឹងកិច្ចស៊ើបសួរ"[65]។ សហមេធាវីចោទប្រកាន់ថា *សកម្មភាពរបស់ក្រុមអ្នកច្បាប់អន្តរជាតិរបស់ ក.ស.ច.ស* ធ្វើឱ្យមានមន្ទិលអំពីសុចរិតភាព ឯករាជ្យភាព និងភាពមិនលម្អៀងរបស់សហចៅក្រមស៊ើបអង្កេត និងការស៊ើបអង្កេតទាំងមូល ហើយថា "ប្រសិនបើមានលេចចេញនូវព័ត៌មានដែលគួរឱ្យជឿជាក់បានណាមួយ បង្ហាញអំពី*កង្វះខាតនូវឯករាជ្យភាព ឬភាពមិនលម្អៀងនៅក្នុង ក.ស.ច.ស*" [redacted] មានសិទ្ធិទទួលបានព័ត៌មាន[66]។ សហមេធាវីស្នើឡើងថា ទាក់ទិននឹងសំណើនេះ *វិធាន ២១ នៃវិធានផ្ទៃក្នុង* តម្រូវឱ្យមានការទទួលយកបណ្តឹងឧទ្ធរណ៍ ដើម្បីការពារសិទ្ធិរបស់ [redacted] *ក្នុងការទទួលបាននូវការស៊ើបអង្កេតដោយយុត្តិធម៌ ឯករាជ្យ និងដោយមិនលម្អៀង*[67]។ នៅក្នុងសំណើសហមេធាវីចោទប្រកាន់ថា នៅក្នុងលិខិតដែលត្រូវបានចោទប្រកាន់ ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ និងបានផ្ញើជូនទៅអគ្គលេខាធិការរងអង្គការសហប្រជាជាតិទទួលបន្ទុកកិច្ចការច្បាប់ ប្រធានផ្នែកច្បាប់របស់ ក.ស.ច.ស "បានសម្តែងនូវការមិនពេញចិត្តពីក្រុមអ្នកច្បាប់អន្តរជាតិរបស់ ក.ស.ច.ស ចំពោះការស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតនៅក្នុងសំណុំរឿង០០៣ និងសេចក្តីសម្រេចបញ្ចប់កិច្ចស៊ើបសួរ ដែលតាមការយល់ឃើញរបស់ពួកគេ គឺវា*ប្រញាប់ប្រញាល់ពេក*" ("លិខិតដែលត្រូវបានចោទប្រកាន់")[68]។ សហមេធាវីយល់ឃើញថា លិខិតដែលត្រូវបានចោទប្រកាន់នេះ ជា "ព័ត៌មានដែលអាចនាំឱ្យមានការមន្ទិលសង្ស័យទៅលើដំណើរការស៊ើបអង្កេត"[69] ហើយដើម្បីឱ្យ [redacted] ទទួលបានសិទ្ធិពេញលេញ ក្នុងការស៊ើបអង្កេតតាមផ្លូវតុលាការមួយដែលត្រឹមត្រូវ ឯករាជ្យ និងមិនលម្អៀង ពួកគាត់ស្នើសុំ*សំណៅថតចម្លងនៃលិខិតនោះ និងឯកសារពាក់ព័ន្ធទាំងអស់* និងស្នើសុំឱ្យដាក់ឯកសារទាំងអស់នេះទៅក្នុងសំណុំរឿង[70]។

---

[65] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៩(ង)។

[66] ដូចយោងខាងលើ។

[67] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៣។ សូមមើលផងដែរ ឯកសារ D87/2/1.6 កថាខណ្ឌ សេចក្តីផ្តើម ដែលយោងទៅលើ វិធាន ២១ នៃវិធានផ្ទៃក្នុង។

[68] ឯកសារ D87/2/1.6 កថាខណ្ឌ ២-៣។

[69] ឯកសារ D87/2/1.6 កថាខណ្ឌ ៤។

[70] ឯកសារ D87/2/1.6 កថាខណ្ឌ សន្និដ្ឋានចុងក្រោយ។

22. ទាក់ទិននឹងសារណារបស់សហមេធាវីដែលថា *សកម្មភាពរបស់បុគ្គលិក*ក.ស.ច.សធ្វើឲ្យប៉ះពាល់ដល់ឯករាជ្យភាព និងភាពអនាគតិរបស់សហចៅក្រមស៊ើបអង្កេតខ្លួនឯងផ្ទាល់នោះ អង្គបុរេជំនុំជម្រះបានសម្រេចរួចហើយថា "ទឡ្ហីករណ៍នេះមិនមានមូលដ្ឋានឡើយ" ហើយថា "តួនាទី និង មុខងាររបស់ [បុគ្គលិក] មានការបែងចែកខុសពីតួនាទី និង មុខងាររបស់សហចៅក្រមស៊ើបអង្កេត[ដែលអនុលោមតាមច្បាប់ជាធរមាន] សហចៅក្រមស៊ើបអង្កេតមាន*សិទ្ធិអំណាច និងការទទួលខុសត្រូវតែម្នាក់ឯងប៉ុណ្ណោះ ក្នុងការដឹកនាំកិច្ចស៊ើបសួររបស់តុលាការ* [...]។ នៅក្នុងកាលៈទេសៈទាំងនេះ ឯករាជ្យភាព និងភាពអនាគតិរបស់សហចៅក្រមស៊ើបអង្កេត បានការពារនូវសិទ្ធិក្នុងការទទួលបាននូវការកាត់សេចក្ដីដោយភាពយុត្តិធម៌របស់ជនត្រូវចោទ"[71]។ ដូចដែលសហមេធាវីបានលើកឡើងផងដែរ អង្គបុរេជំនុំជម្រះកត់សម្គាល់បន្ថែម ទៀតថា សហចៅក្រមស៊ើបអង្កេតក៏បានបញ្ជាក់យ៉ាងច្បាស់ដូចគ្នានេះដែរ ដែលថា ពួកគាត់មាន "ការទទួលខុសត្រូវតែម្នាក់ឯងប៉ុណ្ណោះ" ទាក់ទិននឹងការស៊ើបអង្កេត[72]។ លើសពីនេះទៀត ដូចដែលសហមេធាវីបានលើកឡើងផងដែរ អង្គការសហប្រជាជាតិបានបញ្ជាក់រួចហើយថា អង្គការសហប្រជាជាតិ "នឹងមិនផ្ដល់មតិយោបល់ទៅលើបញ្ហាទាំងឡាយ ដែលស្ថិតនៅក្រោមការពិចារណាតាមផ្លូវតុលាការទេ ហើយក៏មិនសន្និដ្ឋានដោយស្មានទៅលើសកម្មភាព ដែលគួរតែចាត់ការ ឬមិនគួរចាត់ការដោយចៅក្រម ឬព្រះរាជអាជ្ញា នៅក្នុងរឿងក្ដីណាមួយឡើយ"[73]។ ដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា ការយឺតយ៉ាវក្នុងការឆ្លើយតបរបស់ ក.ស.ច.ស ចំពោះសំណើនេះ មិនបានរារាំង [redacted] មិនឲ្យទទួលបានផលប្រយោជន៍ដែលគាត់ចង់បានទេ ដែលជាការស៊ើប អង្កេតមួយដ៏ត្រឹមត្រូវ ឯករាជ្យ និងដោយមិនលម្អៀង។ បណ្ដឹងឧទ្ធរណ៍នេះមិនអាចទទួលយកបាន ដោយផ្អែកមូលដ្ឋានលើការបដិសេធតាមការសន្មតឡើយ។

---

[71] សូមមើលពាក្យសុំរបស់ អៀង សារី ស្នើសុំប្ដឹងជំទាស់ចិត្តអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស Stephen Header និងមន្ត្រីផ្នែកច្បាប់របស់ ក.ស.ច.ស David Boyle នៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេត ថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ ២០០៩ ឯកសារលេខ ១។ សូមមើលផងដែរ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់ ក.ស.ច.ស សម្រេចបដិសេធសំណើរបស់គាត់សុំឲ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបសួរ ដែលធ្វើឡើងដោយ ឬដោយមានជំនួយពីលោក Stephen Heder និងលោក David Boyle និងលើសំណើរបស់លោក អៀង សារី សុំឲ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពភស្តុតាងទាំងឡាយដែលប្រមូលពីមជ្ឈមណ្ឌលឯកសារកម្ពុជា និងបណ្ដឹងឧទ្ធរណ៍បន្ទាន់ប្រឆាំងនឹងការបដិសេធរបស់ ក.ស.ច.ស លើការផ្អាកកិច្ចដំណើរការនីតិវិធី ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១០ ឯកសារ D402/1/4 កថាខណ្ឌ ៣៥-៣៦។

[72] ឯកសារ D87/2/1.6 កថាខណ្ឌ ១១។

[73] ឯកសារ D87/2/1.6 កថាខណ្ឌ ១២។

**សំណើរបស់ [redacted] ស្នើសុំការស្រាយបំភ្លឺអំពីថាតើ ក.ស.ច.ស យល់ឃើញថា ខ្លួនឯងជាប់កាតព្វកិច្ចដោយយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះដែលថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតម្រូវឱ្យមានទំនាក់ទំនងទៅនឹងជម្លោះប្រដាប់អាវុធ ឬយ៉ាងណា ("បញ្ហាស្ដីអំពីទំនាក់ទំនង")**[74]

23. សហមេធាវីលើកឡើងនៅក្នុងបណ្ដឹងឧទ្ធរណ៍ថា សំណើនេះ "ធ្វើឡើងជាការចាំបាច់ដើម្បីផលប្រយោជន៍នៃសច្ចភាពផ្លូវច្បាប់ ដោយសារតែបញ្ហាផ្នែកច្បាប់នេះ *គឺបញ្ហាស្ដីអំពីទំនាក់ទំនង នៅមិនទាន់បានដោះស្រាយរួចនៅឡើយទេនៅ អ.វ.ត.ក*" ពីព្រោះនៅក្នុងសំណុំរឿង ០០២ អង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូង មានការយល់ឃើញផ្សេងគ្នា[75]។ មេធាវីការពារក្ដីស្នើឡើងថា ទាក់ទិននឹងសំណើនេះ *វិធាន ២១ នៃវិធានផ្ទៃក្នុង* តម្រូវឱ្យមានការទទួលយកបណ្ដឹងឧទ្ធរណ៍ ដើម្បីការពារ*សិទ្ធិ*របស់ [redacted] ក្នុងការទទួលបាននូវ*សច្ចភាពផ្លូវច្បាប់*[76]។ នៅក្នុងសំណើ សហមេធាវីស្នើសុំឱ្យមានការស្រាយបំភ្លឺពី ក.ស.ច.ស ស្ដីអំពីគោលជំហររបស់ខ្លួន ទាក់ទិននឹងយុត្តិសាស្ត្រជាធរមានរបស់ អ.វ.ត.ក អំពីបញ្ហាទំនាក់ទំនង ("ផ្នែកបន្ថែមនៃសំណើ")[77] និងអនុញ្ញាតឱ្យមានការដាក់សេចក្ដីសន្និដ្ឋានតាមផ្លូវច្បាប់ "*លើបញ្ហាថាតើ និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងអំឡុងឆ្នាំ ១៩៧៥-៧៩ បានតម្រូវឱ្យមានទំនាក់ទំនងទៅនឹងជម្លោះប្រដាប់អាវុធ ឬយ៉ាងណា* ("ផ្នែកចុងក្រោយនៃសំណើ")[78]។

24. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ក្រៅពីស្នើសុំឱ្យទទួលយកបណ្ដឹងឧទ្ធរណ៍ដោយលើកឡើងថា ការមិនទទួលយកបណ្ដឹងឧទ្ធរណ៍នឹងរំលោភទៅលើ*សិទ្ធិ*របស់ [redacted] ក្នុងការទទួលបាននូវ*សច្ចភាពផ្លូវច្បាប់*នោះ សហមេធាវីពុំបានពន្យល់នៅក្នុងបណ្ដឹងឧទ្ធរណ៍ ឬនៅក្នុងសំណើឡើយថាតើ សិទ្ធិក្នុងការទទួលបានសច្ចភាពផ្លូវច្បាប់ត្រូវបានប៉ះពាល់យ៉ាងដូចម្ដេច តាមរយៈការមិនធ្វើសេចក្ដីប្រកាស របស់សហចៅក្រមស៊ើបអង្កេត *នៅក្នុងដំណាក់កាលនៃការស៊ើបអង្កេតនេះ* ទាក់

---

74 សំណើរបស់ [redacted] ស្នើសុំការស្រាយបំភ្លឺអំពីថាតើ ក.ស.ច.ស យល់ឃើញថាខ្លួនឯង ជាប់កាតព្វកិច្ចដោយយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះដែលថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតម្រូវឱ្យមានទំនាក់ទំនងទៅនឹងជម្លោះប្រដាប់អាវុធ ឬយ៉ាងណា ថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D87/2/1.7។

75 បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ១៩(ខ)។

76 បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ២៣។ សូមមើលផងដែរ ឯកសារ D87/2/1.7 កថាខណ្ឌសេចក្ដីផ្ដើម ដែលយោងទៅវិធាន ២១ នៃវិធានផ្ទៃក្នុង។

77 ឯកសារ D87/2/1.7 កថាខណ្ឌ ចុងក្រោយ (ក) និង (ខ)។

78 ឯកសារ D87/2/1.7 កថាខណ្ឌ ចុងក្រោយ (គ)។

ទិនទៅនឹង*ធាតុ ផ្សំមួយ* នៃឧក្រិដ្ឋកម្មដែល [redacted] ត្រូវបានសង្ស័យថាបានប្រព្រឹត្តដូចជាធាតុផ្សំ "ផ្នែកទំនាក់ទំនង" សម្រាប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនេះ។ ពួកគាត់គ្រាន់តែលើកឡើងនូវក្តីបារម្ភថា "បញ្ហាផ្នែកច្បាប់នេះនៅមិនទាន់ដោះស្រាយរួចនៅឡើយទេនៅ អ.វ.ត.ក"[79]។ សហមេធាវីក៏បានសម្តែងនូវចេតនារបស់ពួកគាត់ ក្នុងការគាំទ្រទស្សនៈរបស់អង្គជំនុំជម្រះមួយ ក្នុងចំណោមអង្គជំនុំជម្រះផ្សេងៗរបស់ អ.វ.ត.ក ពាក់ព័ន្ធនឹង*និយមន័យ* នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។

25. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា បញ្ហា*និយមន័យ*នៃឧក្រិដ្ឋកម្មគឺជាបញ្ហាមួយដែលកម្រិតការអនុវត្តយុត្តាធិការដោយ អ.វ.ត.ក[80]។ ដោយពិចារណាទៅលើគោលបំណង និងលក្ខណៈនៃ*ផ្នែកចុងក្រោយនៃសំណើនេះ* នៅត្រង់ចំណុចដែលសហមេធាវីស្នើសុំដាក់សេចក្តីសន្និដ្ឋានតាមផ្លូវច្បាប់ដោយលើកទឡ្ហីករណ៍អំពីអត្ថិភាពនៃច្បាប់នៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នៃធាតុផ្សំមួយនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អង្គបុរេជំនុំជម្រះយល់ឃើញថា ទឡ្ហីករណ៍នេះពាក់ព័ន្ធសំខាន់ទៅនឹងលក្ខណៈវិនិច្ឆ័យនៃការអនុលោមតាមគោលការណ៍នីត្យានុកូលភាព ដូច្នេះហើយអាចជាបណ្តឹងជំទាស់ផ្នែកយុត្តាធិការ ដោយអាស្រ័យទៅលើថាតើសេចក្តីសន្និដ្ឋានទាំងនោះ ត្រូវបានដាក់នៅចំពោះមុខ អ.វ.ត.ក បែបណា[81]។ ពាក់ព័ន្ធនឹងបញ្ហានេះ អង្គបុរេជំនុំជម្រះបានកត់សម្គាល់រួចហើយ ទាក់ទិននឹងបណ្តឹងឧទ្ធរណ៍ស្រដៀងគ្នាដែលមេធាវីការពារក្តី អៀង សារី ក៏បានដាក់ក្នុងខណៈដែលការស៊ើបអង្កេតក្នុងសំណុំរឿង ០០២ កំពុងតែបន្តនោះ ថា ៖

> "វិធានផ្ទៃក្នុងមិនចងកាតព្វកិច្ចសហចៅក្រមស៊ើបអង្កេតឱ្យសម្រេចបញ្ហា [*ផ្នែកយុត្តាធិការ*] នៅមុនពេលចេញដីកាដំណោះស្រាយនោះទេ [...]។ ប្រសិនបើដីកាដំណោះស្រាយបញ្ជាក់ពីយុត្តាធិការរបស់ អ.វ.ត.ក [...] ជនត្រូវចោទអាចពិចារណាអំពីអានុភាពវិធាន ៦៧(៥) និងវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង នៅពេលអានវិធានទាំងពីរនេះរួមគ្នា។

[79] ឯកសារ D87/2/1.7 កថាខណ្ឌផ្តើម។

[80] សាលដីកា ក្នុងសំណុំរឿង ០០១ កថាខណ្ឌ ១០០។

[81] សូមមើល សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ៨៤។

មកដល់ដំណាក់កាលនេះ វាមិនប្រាកដប្រជានៅឡើយ ថាតើសហចៅក្រមស៊ើបអង្កេតអាចមានការពិចារណាកម្រិតណាចំពោះយុត្តាធិការរបស់ អ.វ.ត.ក [...]។ *សហចៅក្រមស៊ើបអង្កេតមិនជាប់កាតព្វកិច្ចក្នុងការធ្វើសេចក្ដីសម្រេចបកស្រាយច្បាប់* ដូចដែលបានលើកឡើងយ៉ាងមានប្រសិទ្ធភាពនៅក្នុងសំណើសុំនេះទេ ហើយអង្គជំនុំជម្រះនឹងមិនផ្ដល់គំនិតយោបល់បែបប្រឹក្សាណាមួយនោះទេ និងមិនអាចដាក់កំហិតសហចៅក្រមស៊ើបអង្កេតក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ទាក់ទងទៅនឹងសេចក្ដីសម្រេចដែលត្រូវបានបញ្ជាក់ជូននៅក្នុងដីកាដំណោះស្រាយនោះ។

អង្គបុរេជំនុំជម្រះយល់ឃើញថា សិទ្ធិជាមូលដ្ឋានរបស់ជនត្រូវចោទមិនត្រូវបានប៉ះពាល់ដោយការប្រកាសមិនទទួលយកបណ្ដឹងឧទ្ធរណ៍ នៅក្នុងដំណាក់កាលនេះនៃកិច្ចដំណើរការនីតិវិធីទេ ហើយវិធាន ២១ នៃវិធានផ្ទៃក្នុងក៏មិនបានចាប់បង្ខំឲ្យអង្គបុរេជំនុំជម្រះសម្រេចទទួលយកបណ្ដឹងឧទ្ធរណ៍នេះដែរ"[82]។

26. ដោយបានទទួលយកបណ្ដឹងឧទ្ធរណ៍ស្ដីអំពីការជំទាស់ផ្នែកយុត្តាធិការ ដោយបានលើកឡើងយ៉ាងត្រឹមត្រូវដែលជនត្រូវចោទបានដាក់*ប្រឆាំងនឹងដីកាដំណោះស្រាយ*ក្នុងសំណុំរឿង ០០២ នោះ អង្គបុរេជំនុំជម្រះយល់ឃើញថា ក្របខណ្ឌច្បាប់ និងយុត្តិសាស្ត្រជាធរមាន បានការពារសិទ្ធិរបស់ [redacted] ដូច្នេះ វិធាន ២១ នៃវិធានផ្ទៃក្នុង *នៅក្នុងដំណាក់កាលនេះនៃកិច្ចដំណើរការនីតិវិធីនេះ* មិនតម្រូវឲ្យអង្គជំនុំជម្រះបកស្រាយទូលាយអំពីសិទ្ធិប្ដឹងឧទ្ធរណ៍ ដើម្បីទទួលយកបណ្ដឹងឧទ្ធរណ៍ដោយផ្អែកមូលដ្ឋានលើការបដិសេធតាមការសន្និត ឬផ្អែកទៅលើការអះអាងអំពីសិទ្ធិណាមួយដែលមានចែងនៅក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុងនោះឡើយ ពីព្រោះផលប្រយោជន៍ដែលបានស្នើឡើងតាមរយៈសំណើនោះ មិនបានបាត់បង់ដែលមិនអាចស្ដារមកវិញបាននោះឡើយ។

---

[82] សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចលើសំណើរបស់ លោក អៀង សារី ប្រឆាំងនឹងការអនុវត្តទ្រឹស្ដីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារ D345/5/11 កថាខណ្ឌ ១១។

*សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងការបដិសេធតាមការសន្និត់របស់សហចៅក្រមស៊ើបអង្កេតទៅលើសារណារបស់ [redacted] ចំនួនដប់បួនច្បាប់ ដែលបានដាក់ទៅ[ការិយាល័យសហចៅក្រមស៊ើបអង្កេត]*

27. ទាក់ទិននឹងផ្នែក*បន្ថែម* នៃសំណើនោះ អង្គបុរេជំនុំជម្រះ *បញ្ជាក់បំភ្លឺ* ដោយយល់ស្របជាឯកច្ឆ័នជាមួយនឹងការយល់ឃើញរបស់ចៅក្រម Downing និងចៅក្រម Chung របស់អង្គបុរេជំនុំជម្រះ ដូចដែលសហមេធាវីបានកត់សម្គាល់ផងដែរនោះ[83] គឺថា៖

> "ពាក់ព័ន្ធនឹងលក្ខណៈជាកាតព្វកិច្ចនៃសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះទៅលើសហចៅក្រមស៊ើបអង្កេតវិញ យើងយល់ថា គោលការណ៍សុចរិតភាពផ្លូវច្បាប់ និងសមភាពចំពោះមុខច្បាប់ ដែលមានចែងក្នុងវិធានផ្ទៃក្នុង និងជាផ្នែកមួយនៃបទដ្ឋានអន្តរជាតិ ជាគោលការណ៍តម្រូវឱ្យសហចៅក្រមស៊ើបអង្កេតត្រូវអនុវត្តតាម*ភាពសមហេតុផល (ratio decidendi)* នៃសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ដែលជាគោលការណ៍ច្បាប់ដែលសេចក្តីសម្រេចណាមួយត្រូវយកមកសំអាង និងដែលត្រូវអនុវត្តនៅក្នុងករណីស្រដៀងគ្នា ឬមានខ្លឹមសារស្រដៀងគ្នា។ លក្ខណៈជាកាតព្វកិច្ចនេះក៏ត្រូវបានគាំទ្រផងដែរដោយឋានានុក្រមរបស់អង្គបុរេជំនុំជម្រះទៅលើសហចៅក្រមស៊ើបអង្កេត ក្រោមប្រព័ន្ធច្បាប់ អ.វ.ត.ក និងក៏ជាប្រយោជន៍នៃសេដ្ឋកិច្ចតុលាការ និងប្រសិទ្ធភាពនៅក្នុងកិច្ចដំណើរការនីតិវិធី ដោយសារថា សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតជាកម្មវត្ថុនៃការប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះដែលជាគោលការណ៍ត្រូវអនុវត្ត តាមសេចក្តីសម្រេចពីមុនរបស់ខ្លួន អនុលោមទៅតាមបទដ្ឋានដែលមានរៀបរាប់ខាងលើ និងអាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះនឹងច្រានចោលសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលបានងាកចេញពីយុត្តិសាស្ត្រពីមុនរបស់ខ្លួន"[84]។

**សំណើ៖ ដាក់ប្រតិចារិកទាំងស្រុងនៃការស្តាប់ចម្លើយសាក្សីទាំងអស់ទៅក្នុងសំណុំរឿង[85], ស្នើសុំលទ្ធផលការងាររបស់អ្នកស៊ើបអង្កេត ក.ស.ច.ស ដែលពាក់ព័ន្ធនឹងការអនុវត្តការស៊ើបអង្កេតមិនត្រឹមត្រូវនៅក្នុងសំណុំរឿង ០០២[86] និងស្នើសុំឱ្យ ក.ស.ច.ស ស្តាប់ចម្លើយសាក្សីឡើងវិញ[87]**

[83] ឯកសារ D87/2/1.7 កថាខណ្ឌ ១៨។

[84] សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចស្តីពីភាពទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ឈ្មោះ [redacted] ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៣, ឯកសារ D11/3/4/2, កថាខណ្ឌ ១៧។

[85] សំណើរបស់ [redacted] ស្នើសុំឱ្យ ក.ស.ច.ស ដាក់ប្រតិចារិកទាំងស្រុងនៃការស្តាប់ចម្លើយ សាក្សីទាំងអស់ទៅក្នុង[illegible] ថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D87/2/1.8។

*សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងការបដិសេធតាមការសន្មត់របស់សហចៅក្រមស៊ើបអ[illegible] ទៅលើសារណារបស់ [redacted] ចំនួនដប់បួនច្បាប់ ដែលបានដាក់ទៅ[ការិយាល័យសហចៅក្រមស៊ើបអង្កេត]*

28. សហមេធាវីលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍ថា សំណើទាំងនេះធ្វើឡើងជាការចាំបាច់៖ *"ពីព្រោះ* [redacted] *មានសិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ក្នុងការពិនិត្យភស្តុតាងប្រឆាំងនឹងរូបគាត់"* ដោយពួកគាត់តវ៉ាថា គាត់មិនអាចអនុវត្តសិទ្ធិនេះបានទេ *ប្រសិនបើ* "ចម្លើយសាក្សីនៅក្នុងសំណុំរឿង មិនបានឆ្លុះបញ្ចាំងនូវចម្លើយដែលសាក្សីបានផ្តល់ជូនពិតប្រាកដទៅឱ្យអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស"[88] និង "ដោយសារតែមេធាវីការពារក្តីត្រូវពិនិត្យឡើងវិញទៅលើលទ្ធផលការងាររបស់អ្នកស៊ើបអង្កេត ក.ស.ច.ស ទាំងនោះ នៅក្នុងសំណុំរឿង ០០៣ [ដែលត្រូវបានចោទប្រកាន់ថា បានជាប់ពាក់ព័ន្ធនឹងការអនុវត្តការស៊ើបអង្កេតមិនប្រក្រតី ឬមិនត្រឹមត្រូវនៅក្នុងសំណុំរឿង ០០២ បើយោងតាមសហមេធាវី] *ដើម្បីសម្រេចថា តើចាំបាច់ត្រូវដាក់ពាក្យសុំមោឃភាពការបំពេញកិច្ចស៊ើបសួរ អនុលោមតាមវិធាន ៧៦ ឬយ៉ាងណា*"[89]។ សហមេធាវីស្នើឡើងថា ទាក់ទិននឹងសំណើទាំងនេះ *វិធាន ២១ នៃវិធានផ្ទៃក្នុង* តម្រូវឱ្យមានការទទួលយកបណ្តឹងឧទ្ធរណ៍ ដើម្បីការពារ*សិទ្ធិ* របស់ [redacted] ក្នុងការពិនិត្យមើលភស្តុតាងប្រឆាំងនឹងរូបគាត់[90] និងសិទ្ធិទទួលបានកិច្ចដំណើរការនីតិវិធីប្រកបដោយយុត្តិធម៌ និងតម្លាភាព[91]។ នៅក្នុងសំណើ សហមេធាវីស្នើសុំ៖ ឱ្យ ក.ស.ច.ស ដាក់ប្រតិចារឹកទាំងស្រុងនៃការស្តាប់ចម្លើយសាក្សីទាំងអស់ ទៅក្នុងសំណុំរឿង និង*ផ្តល់ប្រតិចារឹកនៃការស្តាប់ចម្លើយសាក្សីទាំងនោះទៅឱ្យមេធាវីការពារក្តី*[92], ឱ្យ ក.ស.ច.ស *ផ្តល់ឱ្យមេធាវីការពារក្តីនូវលទ្ធផលការងាររបស់អ្នកស៊ើបអង្កេត ក.ស.ច.ស ទាំងអស់ដែល* ក.ស.ច.ស មានហេតុផលជឿជាក់ថា អាចបានអនុវត្តវិធីសាស្ត្រស៊ើបអង្កេតមិនប្រក្រតី និងមិនត្រឹមត្រូវ[93] និងឱ្យ ក.ស.ច.ស ពិនិត្យការស្តាប់ចម្លើយសាក្សីទាំងអស់នៅក្នុងសំណុំរឿង, សម្រេចថាតើ សាក្សីណាខ្លះអាចត្រូវបានស្តាប់ចម្លើយឡើងវិញ ហើយនៅក្នុងកម្រិតណា,

[86] សំណើរបស់ [redacted] ស្នើសុំលទ្ធផលការងាររបស់អ្នកស៊ើបអង្កេត ក.ស.ច.ស ដែលពាក់ព័ន្ធនឹងការអនុវត្តការស៊ើបអង្កេតមិនត្រឹមត្រូវនៅក្នុងសំណុំរឿង ០០២ ថ្ងៃទី ៦ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D87/2/1.9។

[87] សំណើរបស់ [redacted] ស្នើសុំឱ្យ ក.ស.ច.ស ស្តាប់ចម្លើយសាក្សីឡើងវិញ ថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D87/2/1.14។

[88] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៩(ក) និង (ខ)។

[89] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៩(ជ)។

[90] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៣។ សូមមើលផងដែរ ឯកសារ D87/2/1.8 និង D87/2/1.14 កថាខណ្ឌ សេចក្តីផ្តើម។

[91] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៣។ សូមមើលផងដែរ ឯកសារ D87/2/1.9 និង D87/2/1.14 កថាខណ្ឌ សេចក្តីផ្តើម។

[92] ឯកសារ D87/2/1.8 កថាខណ្ឌ ២០។

[93] ឯកសារ D87/2/1.9 កថាខណ្ឌ ១៧។

ស្តាប់ចម្លើយជាថ្មីទៀត ប្រសិនបើចាំបាច់ និង*ដាក់លទ្ធផលនៃការវាយតម្លៃនេះ* ទៅក្នុងសំណុំរឿង[94]។

29. អង្គបុរេជំនុំជម្រះ ជាដំបូងកត់សម្គាល់ថា សហមេធាវីពុំទាន់មានសិទ្ធិចូលពិនិត្យមើលសំណុំរឿង ០០៣ នៅឡើយទេ។ ទីពីរ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា *ការចោទប្រកាន់* របស់សហមេធាវី ចំពោះការអនុវត្តការស៊ើបអង្កេតមិនប្រក្រតី ឬមិនត្រឹមត្រូវ ដែលធ្វើឡើងដោយអ្នកស៊ើបអង្កេត ក.ស.ច.ស នៅក្នុងសំណុំរឿង ០០៣ មានមូលដ្ឋានទៅលើសេចក្តីប្រកាសដែលធ្វើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ Cayley[95] នៅពេលស្នើសុំសេចក្តីណែនាំពីអង្គជំនុំជម្រះសាលាដំបូង ទាក់ទិននឹងការបង្ហាញចម្លើយសាក្សីនានា ដែលបានមកពីសំណុំរឿង ០០៣ និង ០០៤ ដែលមានខ្លឹមសារដូចខាងក្រោមនេះ៖

> “សហព្រះរាជអាជ្ញាអន្តរជាតិ បានពិនិត្យឡើងវិញនូវកំណត់ហេតុស្តាប់ចម្លើយថ្មីៗទាំងនេះក្នុងសំណុំរឿង ០០២ និងបានកត់សម្គាល់ឃើញនូវ*ភាពមិនស្របគ្នា ឬចន្លោះប្រហោងមួយចំនួន នៅពេលធ្វើការប្រៀបធៀបចម្លើយសាក្សីនានា នៅក្នុងសំណុំរឿង ០០៣ និង ០០៤ ទៅនឹងខ្សែអាត់ថតសំឡេងនៃការធ្វើសម្ភាសន៍ទាំងនោះ* ហេតុដូចនេះ ការបង្ហាញជូនណាមួយដែលមានការណែនាំពីអង្គជំនុំជម្រះសាលាដំបូង គួរតែរួមបញ្ចូលទាំងខ្សែអាត់ថតសំឡេងនៃការធ្វើសម្ភាសន៍ទាំងនោះផងដែរ”[96]។

30. បន្ទាប់ពីមានសេចក្តីប្រកាសនេះពីសហព្រះរាជអាជ្ញាអន្តរជាតិរួចមក សហមេធាវីជំទាស់នៅក្នុងសំណើរបស់ខ្លួនថា “ដូច្នេះ មេធាវីការពារក្តីមាន *ហេតុផលត្រឹមត្រូវក្នុងការជឿជាក់* ថា កិច្ចស៊ើបសួរ *មួយចំនួន* ដែលធ្វើឡើងនៅក្នុងសំណុំរឿង ០០៣ *អាច*ត្រូវបានរងការប៉ះពាល់ ដោយសារតែវិធីសាស្ត្រស៊ើបអង្កេតមិនត្រឹមត្រូវ ដែលនាំឱ្យមានកំហុសផ្នែកនីតិវិធី[97]។

31. ដូចដែលបានកត់សម្គាល់ដោយសហមេធាវីនៅក្នុងសំណើរបស់ពួកគាត់ អង្គបុរេជំនុំជម្រះ ជាដំបូងកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២ បានបដិសេធមិនបំពេញកិច្ច

---

[94] ឯកសារ D87/2/1.14 កថាខណ្ឌ ៦។

[95] ឯកសារ D87/2/1.8 កថាខណ្ឌ ១ យោងទៅឯកសារ E127 ។ ឯកសារ D87/2/1.9 កថាខណ្ឌ ១ យោងទៅឯកសារ E127។ ឯកសារ D87/2/114 កថាខណ្ឌ ១ យោងទៅឯកសារ E127។

[96] ឯកសារ E127 កថាខណ្ឌ ១៤។

[97] ឯកសារ D87/2/1.9 កថាខណ្ឌ ១៣។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

ស៊ើបសួរ អនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង និងយល់ឃើញថា មេធាវីការពារក្តីមិនបានធ្វើឱ្យអង្គជំនុំជម្រះជឿជាក់ឡើយថា ចំណុចខ្វះចន្លោះដែលត្រូវបានចោទប្រកាន់ មិនអាចត្រូវបានរកឃើញក្នុងអំឡុងដំណាក់កាលស៊ើបអង្កេត *ឬថា បុគ្គលិករបស់ ក.ស.ច.ស ពិតជាបានបំភ្លៃងកំណត់ហេតុនៃកិច្ចស៊ើបសួរដោយចេតនាពិតប្រាកដឡើយ*[98]។ ទាក់ទិននឹងការចោទប្រកាន់ថ្មីៗនេះ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ដោយពុំមានសិទ្ធិចូលពិនិត្យសំណុំរឿង ០០៣ នោះ សហមេធាវីពុំទាន់មានសិទ្ធិធ្វើសំណើ *ជាក់លាក់* ប្រភេទណាមួយនៅឡើយទេ ទោះបីជាទាក់ទិននឹងការអនុវត្តការស៊ើបអង្កេតមិនត្រឹមត្រូវ ឬក៏ទាក់ទិននឹងមោឃភាពនៃផ្នែក *ជាក់លាក់* ណាមួយ នៃកិច្ចស៊ើបសួរក៏ដោយ។ ដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា សំណើទាំងនេះគឺជាការប្រញាប់ប្រញាល់ពេក។

32. អាស្រ័យហេតុនេះ ដោយយោងទៅលើហេតុផលដែលបានបញ្ជាក់ជូនខាងលើ អង្គបុរេជំនុំជម្រះយល់ឃើញថា ការយឺតយ៉ាវក្នុងការឆ្លើយតបរបស់ ក.ស.ច.ស ចំពោះសំណើទាំងនេះ មិនរារាំងអ្នកស្នើសុំមិនឱ្យទទួលបានផលប្រយោជន៍ដែលបានស្នើឡើងនោះទេ ដែលជាលទ្ធភាពពិនិត្យមើលសំណុំរឿង ហើយប្រសិនបើចាំបាច់ លទ្ធភាពរៀបចំការស្នើសុំមោឃភាពកិច្ចស៊ើបសួរ ដោយអនុលោមតាមវិធាន ៧៦ នៅពេលដែលខ្លួនត្រូវបានអនុញ្ញាតឱ្យចូលពិនិត្យមើលសំណុំរឿង។ បើទោះជាមានការយឺតយ៉ាវ ក្នុងការសម្រេចទៅលើបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងសំណើសុំពិនិត្យសំណុំរឿងក្តី ក៏អង្គបុរេជំនុំជម្រះយល់ថា សំណើទាំងនេះមិនធ្វើឱ្យបណ្តឹងឧទ្ធរណ៍ត្រូវបានទទួលយកដោយផ្អែកមូលដ្ឋានទៅលើការបដិសេធតាមការសន្មត ឬទៅលើសិទ្ធិទាំងឡាយដែលត្រូវបានអះអាងថា ទទួលបានពីវិធាន ២១ នៃវិធានផ្ទៃក្នុងនោះឡើយ។

**សំណើសុំលក្ខណវិនិច្ឆ័យរបស់ ក.ស.ច.ស ពាក់ព័ន្ធនឹង "មេដឹកនាំជាន់ខ្ពស់របស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត"**[99]

33. សហមេធាវីលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍ថា សំណើនេះធ្វើឡើងជាការចាំបាច់៖ "ពីព្រោះមេធាវីការពារក្តី ក្នុងការបំពេញ*ភារកិច្ចរបស់ខ្លួនដោយយកចិត្តទុកដាក់ អាចត្រូវការដាក់សារណាជំទាស់ទៅនឹងការរំលោភឥទ្ធានុសិទ្ធិដោយ ក.ស.ច.ស នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនក្នុងការស៊ើបអង្កេតលោក* [redacted] ដូចដែលបានអនុញ្ញាតដោយយុត្តិសាស្ត្ររបស់

---

[98] ឯកសារ D87/2/1.8 កថាខណ្ឌ ៣ យោងទៅឯកសារ E142/3 កថាខណ្ឌ ៨, ១៣។

[99] សំណើរបស់ [redacted] ស្នើសុំលក្ខណៈវិនិច្ឆ័យ ពាក់ព័ន្ធនឹង "មេដឹកនាំជាន់ខ្ពស់របស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D87/2/1.10។

អ.វ.ត.ក"[100]។ មេធាវីការពារក្តីស្នើឡើងថា ទាក់ទិននឹងសំណើទាំងនេះ វិធាន ២១ នៃវិធានផ្ទៃក្នុង តម្រូវឲ្យមានការទទួលយកបណ្តឹងឧទ្ធរណ៍ ដើម្បីការពារសិទ្ធិរបស់ [redacted] ក្នុងការទទួលបាន កិច្ចដំណើរការនីតិវិធីប្រកបដោយយុត្តិធម៌ និងតម្លាភាព[101]។ នៅក្នុងសំណើ សហមេធាវីបានស្នើ ថា៖ ឲ្យ ក.ស.ច.ស ផ្តល់លក្ខណវិនិច្ឆ័យ *"របស់ខ្លួន"* សម្រាប់កំណត់ថាតើ ជនសង្ស័យអាចត្រូវ បានចាត់ទុកថាជា "មេដឹកនាំជាន់ខ្ពស់របស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួល ខុសត្រូវ ខ្ពស់បំផុតដែរឬទេ "រួមទាំងលក្ខណវិនិច្ឆ័យដែលបានកំណត់ និង ប្រើប្រាស់ដោយសហ ចៅក្រមស៊ើបអង្កេត*ម្នាក់ៗ* និងឲ្យ ក.ស.ច.ស ដាក់*លក្ខណវិនិច្ឆ័យទាំងនេះ ទៅក្នុងសំណុំរឿង*[102]។

34. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ការស៊ើបអង្កេតកំពុងតែដំណើរការ និងយល់ឃើញថា ច្បាប់ជាធរមានមិនចងកាតព្វកិច្ចសហចៅក្រមស៊ើបអង្កេត ក្នុងការធ្វើសេចក្តីបញ្ជាក់បកស្រាយច្បាប់ ឬសម្រេចចំពោះលក្ខណវិនិច្ឆ័យ ដែលត្រូវយកមកប្រើនៅក្នុងការជ្រើសរើសជនណាដែលត្រូវ*ចោទប្រកាន់* ឬមិនត្រូវចោទប្រកាន់នោះឡើយ នៅក្នុងដំណាក់កាលនេះនៃកិច្ចដំណើរការនីតិវិធី មុនពេលចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ប្រសិនបើមានដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះ។ នៅពេលមានការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ប្រសិនបើមានដីកានេះ ជនត្រូវចោទអាចពិចារណាទៅលើអានុភាពនៃយុត្តិសាស្ត្ររបស់ អ.វ.ត.ក ក្នុងការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងការរំលោភឆន្ទានុសិទ្ធិ ដោយសហចៅក្រមស៊ើបអង្កេតដែលត្រូវបានចោទប្រកាន់ នៅក្នុងការអនុវត្តនយោបាយចោទប្រកាន់របស់ខ្លួន ប្រសិនបើពួកគាត់យល់ថា ជាការត្រឹមត្រូវ។ អង្គបុរេជំនុំជម្រះយល់ឃើញថា អត្ថិភាពនៃដំណោះស្រាយបែបនេះ គឺគ្រប់គ្រាន់ដើម្បីការពារសិទ្ធិរបស់ [redacted] នៅទីបញ្ចប់ក្នុងការទទួលបានកិច្ចដំណើរការនីតិវិធីប្រកបដោយយុត្តិធម៌ ហើយថា សហមេធាវីពុំបានចង្អុលបង្ហាញឡើយថា ដំណោះស្រាយដែលពួកគាត់បានស្នើសុំនោះ ត្រូវបានរារាំងដោយសារ ក.ស.ច.ស ពន្យារពេលក្នុងការសម្រេចទៅលើសំណើនោះ។

---

[100] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៩(ឈ)។

[101] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៣។ សូមមើលផងដែរ ឯកសារ D87/2/1.10 កថាខណ្ឌ សេចក្តីផ្តើម។

[102] ឯកសារ D87/2/1.10 ទំព័រ ៩ កថាខណ្ឌ ២២(ក) និង (ខ)។

35. ដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា នៅក្នុងដំណាក់កាលនេះ សំណើនេះគឺជាការប្រញាប់ប្រញាល់ពេក ហើយថា វិធាន ២១ នៃវិធានផ្ទៃក្នុងមិនបានចាប់បង្ខំឱ្យអង្គបុរេជំនុំជម្រះសម្រេចទទួលយកបណ្តឹងឧទ្ធរណ៍នេះ ដោយផ្អែកទៅលើមូលដ្ឋាននៃការបដិសេធតាមការសន្មតនោះឡើយ។

**សំណើសុំឱ្យ ក.ស.ច.ស បង្ខំឱ្យ ក.ស.ព ផ្តល់ឱ្យមេធាវីការពារក្តីនូវលក្ខណៈវិនិច្ឆ័យរបស់ខ្លួនពាក់ព័ន្ធនឹង "មេដឹកនាំជាន់ខ្ពស់របស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត"**[103]

36. សហមេធាវីលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍ថា សំណើនេះធ្វើឡើងជាការចាំបាច់ "ពីព្រោះមេធាវីការពារក្តី ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនដោយយកចិត្តទុកដាក់ អាចត្រូវការដាក់សារណាជំទាស់ទៅនឹងការរំលោភឆន្ទានុសិទ្ធិដោយ ក.ស.ព នៅក្នុង*សេចក្តីសម្រេចរបស់ខ្លួនក្នុងការចោទប្រកាន់* [redacted] ដូចដែលបានអនុញ្ញាតដោយយុត្តិសាស្ត្ររបស់ អ.វ.ត.ក"[104]។ សហមេធាវីស្នើឡើងថា ទាក់ទិននឹងសំណើនេះ *វិធាន ២១ នៃវិធានផ្ទៃក្នុង* តម្រូវឱ្យមានការទទួលយកបណ្តឹងឧទ្ធរណ៍ ដើម្បីការពារ*សិទ្ធិ*របស់ [redacted] ក្នុងការទទួលបានកិច្ចដំណើរការនីតិវិធីប្រកបដោយយុត្តិធម៌ និងតម្លាភាព[105]។ នៅក្នុងសំណើ សហមេធាវីស្នើឱ្យ ក.ស.ច.ស បង្ខំឱ្យសហព្រះរាជអាជ្ញាផ្តល់នូវលក្ខណៈវិនិច្ឆ័យរបស់ខ្លួនសម្រាប់កំណត់ថាតើ ជនសង្ស័យអាចត្រូវបានចាត់ទុកថាជា "មេដឹកនាំជាន់ខ្ពស់របស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតដែរឬទេ "រួមទាំងអនុស្សរណៈគតិយុត្តិទាំងអស់ និងឱ្យដាក់សម្ភារនេះទៅក្នុងសំណុំរឿង"[106]។ សហមេធាវីលើកឡើងថា "សម្ភារដែលបានស្នើសុំនេះ មានសារៈសំខាន់ណាស់ ក្នុងការសម្រេចអំពីថាតើ សហព្រះរាជអាជ្ញាបានអនុវត្តដោយពុំសុទ្ធចិត្ត ឬមិនស្របទៅតាមការវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈត្រឹមត្រូវ *ពាក់ព័ន្ធនឹងបញ្ហាថាតើលោក* [redacted] អាចត្រូវបានចាត់ទុកថា ជា

---

[103] សំណើរបស់ [redacted] ស្នើសុំឱ្យ ក.ស.ច.ស បង្ខំឱ្យ ក.ស.ព ផ្តល់ឱ្យមេធាវីការពារក្តីនូវលក្ខណៈវិនិច្ឆ័យរបស់ខ្លួនពាក់ព័ន្ធនឹង "មេដឹកនាំជាន់ខ្ពស់របស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសា D87/2/1.11។

[104] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៩ (ញ)។

[105] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៣។ សូមមើលផងដែរ ឯកសារ D87/2/1.11 កថាខណ្ឌ សេចក្តីផ្តើម។

[106] ឯកសារ D87/2/1.11 កថាខណ្ឌ ១៣(ក) និង(ខ)។

មេដឹកនាំជាន់ខ្ពស់ ឬជាជនម្នាក់ក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតដែរឬទេ"[107]។

37. ដោយយោងទៅលើហេតុផលដែលបញ្ជាក់ជូនបន្ទាប់ទៅទៀតនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា សំណើនេះ (ឯកសារ D87/2/1.11) ត្រូវបានស្រូបបញ្ចូលជាមួយនឹងសំណើពីមុន (ឯកសារ D87/2/1.10) ហើយថា នៅក្នុងដំណាក់កាលនេះ សំណើទាំងពីរនេះ គឺជាការប្រញាប់ប្រញាល់ពេក។

38. ជាដំបូង អង្គបុរេជំនុំជម្រះកត់សម្គាល់ថា "ដោយហេតុថា *ឧក្រិដ្ឋកម្ម* ដែលត្រូវបានចោទប្រកាន់ស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញា មាន*ឆន្ទានុសិទ្ធិទូលំទូលាយ* ក្នុងការបំពេញ*ភារកិច្ចរបស់ខ្លួនទៅតាមច្បាប់*"[108]។ ភារកិច្ចតាមផ្លូវច្បាប់របស់សហព្រះរាជអាជ្ញាដែលស្ថិតក្រោមរបប អ.វ.ត.ក រួមមានការចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ប្រសិនបើសហព្រះរាជអាជ្ញា "មានហេតុផលជឿថា *ឧក្រិដ្ឋកម្ម* ដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក បានកើតមានពិត"[109]។ ប្រសិនបើសហព្រះរាជអាជ្ញារកឃើញថា ពិតជាមានឧក្រិដ្ឋកម្មមែន ក្នុងអំឡុង*ការស៊ើបអង្កេតបឋម*របស់ខ្លួន សហព្រះរាជអាជ្ញាត្រូវបើកការស៊ើបសួរ ដោយបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទៅសហចៅក្រមស៊ើបអង្កេត។ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ក្របខណ្ឌច្បាប់បញ្ជាក់ច្បាស់ណាស់ថា នៅ អ.វ.ត.ក ការផ្តោតជាចម្បងរបស់សហព្រះរាជអាជ្ញាអំពីការស៊ើបអង្កេតបឋមរបស់ខ្លួន គឺដើម្បីកំណត់ភស្តុតាងដែលបង្ហាញអំពីការប្រព្រឹត្ត *ឧក្រិដ្ឋកម្ម* ដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ចំណែកឯ*អត្តសញ្ញាណជនសង្ស័យ* គឺជាការផ្តោតបន្ទាប់[110] ឬជាជម្រើស[111]។

---

[107] ឯកសារ D87/2/1.11កថាខណ្ឌ ១២។

[108] សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ក្នុងសំណុំរឿង ០០១ ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារលេខ F28 កថាខណ្ឌ ៨០។ (សាលដីកា ក្នុងសំណុំរឿង ០០១)

[109] វិធាន ៥៣(១) នៃវិធានផ្ទៃក្នុង។

[110] វិធាន ៥០(១) នៃវិធានផ្ទៃក្នុង ផ្នែកចុងក្រោយនៃប្រយោគ។

[111] វិធាន ៥៣(១)(ឃ) នៃវិធានផ្ទៃក្នុង៖ "ឈ្មោះរបស់បុគ្គលដែលត្រូវធ្វើការស៊ើបអង្កេត *ប្រសិនបើមាន*" (គូស... បន្ថែម)។

39. ប្រសិនបើសហព្រះរាជអាជ្ញាឈានទៅដល់ការឯកភាពគ្នា ក្នុងការបើកកិច្ចស៊ើបសួរចំពោះឧក្រិដ្ឋកម្មដែលស្ថិតក្រោមយុត្តាធិការរបស់ អ.វ.ត.ក និង*កំណត់អត្តសញ្ញាណជនសង្ស័យ* នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនោះ ខ្លឹមសារ[112] នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ មានលក្ខណៈគ្រប់គ្រាន់ ដើម្បីឲ្យគេយល់បានអំពីរបៀបដែលសហព្រះរាជអាជ្ញាបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន។ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា សហមេធាវីបានទទួលការជូនដំណឹងរួចហើយ រួមជាមួយនឹងសំណៅថតចម្លងនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា។

40. ប្រសិនបើសហព្រះរាជអាជ្ញាមិនអាចឈានទៅដល់ការឯកភាពគ្នាទេនោះ ទោះបីជាមានការខ្វែងគំនិតគ្នាយ៉ាងណាក៏ដោយ មាត្រា ៦(៤) នៃកិច្ចព្រមព្រៀង និងមាត្រា ២០ (កថាខណ្ឌទីពីរ និងទីបី) នៃច្បាប់ អ.វ.ត.ក បង្គាប់ថា "ការចោទប្រកាន់*ត្រូវធ្វើបន្តទៅមុខទៀត*" លើកលែងតែសហព្រះរាជអាជ្ញាទាំងពីរនេះ ឬសហព្រះរាជអាជ្ញាណាមួយក្នុងចំណោមសហព្រះរាជអាជ្ញាទាំងពីរធ្វើការស្នើសុំនៅក្នុងរយៈពេលសាមសិបថ្ងៃ ឲ្យអង្គបុរេជំនុំជម្រះដោះស្រាយការខ្វែងគំនិតនេះ។

41. ប្រសិនបើការខ្វែងគំនិតគ្នាត្រូវបាននាំយកទៅដាក់ចំពោះមុខអង្គបុរេជំនុំជម្រះ ហើយពុំមានមតិភាគច្រើន ដូចតម្រូវឲ្យមានចំពោះការធ្វើសេចក្ដីសម្រេចទេ មាត្រា ៧(៤) នៃកិច្ចព្រមព្រៀង និងមាត្រា ២០ (កថាខណ្ឌទី៧) នៃច្បាប់ អ.វ.ត.ក បង្គាប់ថា ការស៊ើបអង្កេត ឬការចោទប្រកាន់*ត្រូវធ្វើបន្តទៅទៀត*'[113]។ នេះមានន័យថា លើកលែងតែសហព្រះរាជអាជ្ញាឈានទៅដល់ការឯកភាពគ្នាទោះស្ថិតនៅក្នុងកាលៈទេសៈណាក៏ដោយ លទ្ធផលចុងក្រោយគឺថា ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរត្រូវដាក់ជូនទៅសហចៅក្រមស៊ើបអង្កេត ដើម្បីបើកកិច្ចស៊ើបសួរ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនេះ អាចមានឈ្មោះជនសង្ស័យដែលត្រូវ*បានកំណត់អត្តសញ្ញាណ ប្រសិនបើអាចធ្វើទៅបាន*។ ជាថ្មីម្ដងទៀត ខ្លឹមសារនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ មានលក្ខណៈគ្រប់គ្រាន់ ដើម្បីឲ្យគេយល់បាននូវរបៀបដែលសហព្រះរាជអាជ្ញាណាម្នាក់ ក្នុងចំណោមសហព្រះរាជអាជ្ញាទាំងពីរនោះបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន។

42. លើសពីនេះទៀត ប្រសិនបើការខ្វែងគំនិតគ្នាត្រូវបាននាំយកទៅដាក់ចំពោះមុខអង្គបុរេជំនុំជម្រះ តួនាទីរបស់អង្គបុរេជំនុំជម្រះ គឺ*ត្រូវដោះស្រាយបញ្ហាជាក់លាក់* ដែលសហព្រះរាជអាជ្ញាមិនស្រប

[112] សូមមើល វិធាន ៥៣(១)(ក), (ខ), (គ) និង (ឃ)។

[113] សូមមើលផងដែរ សេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះលើការខ្វែងគំនិតគ្នារវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន៧១ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ (សេចក្ដីពិចារណាលើការខ្វែងគំនិតគ្នារវាងសហព្រះរាជអាជ្ញា)

*សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងការបដិសេធតាមការសន្មត់របស់សហចៅក្រមស៊ើបអង្កេត ទៅលើសារណារបស់ [redacted] ចំនួនដប់បួនច្បាប់ ដែលបានដាក់ទៅ[ការិយាល័យសហចៅក្រមស៊ើបអង្កេត]*

គ្នានោះ *ដោយធ្វើការពិចារណាលើអង្គហេតុ និងហេតុផលដែលបានលើកឡើង* នៅចំពោះមុខអង្គបុរេជំនុំជម្រះ[114]។ "តួនាទីរបស់អង្គបុរេជំនុំជម្រះនៅក្នុងការដោះស្រាយករណីខ្វែងយោបល់គ្នា ពុំបានធ្វើឱ្យមានការកែប្រែដល់សេចក្តីសន្និដ្ឋានថា ពាក្យពេចន៍ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" នេះ មិនមែនជាលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការរបស់ អ.វ.ត.ក នោះទេ"[115]។ ប្រសិនបើមានមតិភាគច្រើន ដូចតម្រូវឱ្យមានចំពោះការធ្វើសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះទៅលើការខ្វែងគំនិតគ្នារបស់សហព្រះរាជអាជ្ញានោះ ខ្លឹមសារនៃសេចក្តីសម្រេចបែបនេះ គឺមានលក្ខណៈគ្រប់គ្រាន់ ដើម្បីឱ្យគេយល់បាននូវរបៀបដោះស្រាយការខ្វែងគំនិតគ្នានេះ។

43. ជាមួយនឹងការកត់សម្គាល់ពីខាងលើ ទោះជាយ៉ាងណា អង្គបុរេជំនុំជម្រះកត់សម្គាល់បន្ថែមទៀតថា ជាការសំខាន់ត្រូវចងចាំថា នៅក្រោមរបបគតិយុត្តិរបស់ អ.វ.ត.ក មិនដូច ជាប្រព័ន្ធច្បាប់កុំមិនឡ (common law) ឡើយ សហចៅក្រមស៊ើបអង្កេត មិនមែនសហព្រះរាជអាជ្ញាទេ ដែលមាន*អំណាចចុងក្រោយក្នុងការចោទប្រកាន់* ឬមិនចោទប្រកាន់ បុគ្គលណាម្នាក់នោះ ហើយថា ក្នុងការអនុវត្តអំណាចនេះ ដីកាសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា *មិនចង* សហចៅក្រមស៊ើបអង្កេតឡើយ"[116]។ ទោះបីជាសហចៅក្រមស៊ើបអង្កេតត្រូវសួរយោបល់សហព្រះរាជអាជ្ញា មុនពេលចោទប្រកាន់ *បុគ្គលណាម្នាក់ដែលពុំមានឈ្មោះ* នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក៏ដោយ[117] ក៏*អំណាច* ចុងក្រោយក្នុង*ការបញ្ជូនបុគ្គលណាម្នាក់ទៅជំនុំជម្រះ* គឺស្ថិតនៅលើសហចៅក្រមស៊ើបអង្កេត[118]។ ក្រោមកាលៈទេសៈទាំងនេះ នៅ អ.វ.ត.ក សហព្រះរាជអាជ្ញាមានឆន្ទានុសិទ្ធិដំបូងគេ ក្នុង*ការសម្រេចដាក់បុគ្គលណាម្នាក់ជាជនសង្ស័យ និងកំណត់បទចោទបឋមប្រឆាំងនឹងបុគ្គលនោះ*[119] ហើយចុងក្រោយ ឆន្ទានុសិទ្ធិនេះត្រូវធ្លាក់មកលើសហចៅក្រមស៊ើបអង្កេតនៅពេលបញ្ចប់កិច្ចស៊ើបសួរក្នុងការសម្រេចធ្វើការ*ចោទប្រកាន់ ឬមិនចោទប្រកាន់* បុគ្គលណាម្នាក់ នៅក្នុងករណីដែល ៖ ១) អំពើដែលចោទប្រកាន់រាប់ចូលជាបទឧក្រិដ្ឋដែលស្ថិតនៅក្រោមយុត្តាធិការនៃ អ.វ.ត.ក ហើយថា ២) ក្នុងចំណោម បុគ្គលទាំងឡាយដែលត្រូវបានកំណត់

---

[114] សេចក្តីពិចារណាលើការខ្វែងគំនិតគ្នារវាងសហព្រះរាជអាជ្ញា កថាខណ្ឌ ២៤។

[115] សាលដីកា ក្នុងសំណុំរឿង ០០១ កថាខណ្ឌ ៦៥។

[116] វិធាន ៦៧(១) នៃវិធានផ្ទៃក្នុង

[117] វិធាន ៥៥(៤) នៃវិធានផ្ទៃក្នុង។

[118] វិធាន ៦៧(១) នៃវិធានផ្ទៃក្នុង។

[119] វិធាន ៥០(១) នៃវិធានផ្ទៃក្នុង។

អត្តសញ្ញាណថាជាជនប្រព្រឹត្តបទឧក្រិដ្ឋទាំងនោះ សហចៅក្រមស៊ើបអង្កេតសម្រេចធ្វើការចោទប្រកាន់បុគ្គលតែមួយចំនួនតូចប៉ុណ្ណោះ។

44. ដូច្នេះ ដោយយោងទៅលើហេតុផលទាំងនេះ និងដោយយោងទៅលើហេតុផលដែលបានបញ្ជាក់នៅក្នុងកថាខណ្ឌ ៣៤ ខាងលើ អង្គបុរេជំនុំជម្រះយល់ឃើញថា៖ សំណើនៅក្នុងឯកសារ D87/2/1.11 ត្រូវបានស្របបញ្ចូលជាមួយនឹងសំណើនៅក្នុងឯកសារ D87/2/1.10, ថា នៅក្នុងដំណាក់កាលនេះនៃនីតិវិធី សំណើទាំងនេះ គឺជាការប្រញាប់ប្រញាល់ពេក, ថា ក្របខណ្ឌច្បាប់ និងយុត្តិសាស្ត្រការពារសិទ្ធិរបស់ [redacted] ក្នុងការទទួលបានកិច្ចដំណើរការនីតិវិធីប្រកបដោយយុត្តិធម៌ តាមរយៈការផ្តល់នូវដំណោះស្រាយ និងយល់ឃើញថា ដូច្នេះ វិធាន ២១ នៃវិធានផ្ទៃក្នុងមិននាំឲ្យអង្គជំនុំជម្រះទទួលយកបណ្តឹងឧទ្ធរណ៍នេះ ដោយផ្អែកមូលដ្ឋានលើការបដិសេធតាមការសន្មត ឬបើមិនដូច្នេះទេ ត្រូវពិចារណាលើបញ្ហានេះនៅក្នុងដំណាក់កាលនេះ ។

**សំណើសុំការបញ្ជាក់ពាក់ព័ន្ធនឹង ថាតើមេធាវីការពារក្តីអាចធ្វើការស៊ើបអង្កេតនៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនាពេលបច្ចុប្បន្ននេះ ឬយ៉ាងណា**[120]

45. សហមេធាវីលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍ថា សំណើនេះធ្វើឡើងជាការចាំបាច់ " ដើម្បីការពារសិទ្ធិរបស់ [redacted] ក្នុងការមាន*ពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីត្រៀមរៀបចំការពារខ្លួនរបស់គាត់ និងសិទ្ធិក្នុងការទទួលបាននូវសមភាពនៃមធ្យោបាយក្នុងការតទល់ក្តី* [...] ដោយសារតែ ក.ស.ច.ស ពុំទទួលស្គាល់ [redacted] ជាភាគីមួយនៃកិច្ចដំណើរការនីតិវិធី និងកំពុងតែបដិសេធមិនឲ្យគាត់ចូលទៅពិនិត្យសំណុំរឿង និងមិនឲ្យគាត់មានសមត្ថភាពក្នុងការចូលរួមក្នុងកិច្ចស៊ើបសួរនោះ វាបង្ហាញឲ្យឃើញយ៉ាងសមហេតុផលថា [redacted] និងសហមេធាវីរបស់គាត់*គួរតែមានសេរីភាពក្នុងការធ្វើការស៊ើបអង្កេតដោយខ្លួនឯងផ្ទាល់* ទាក់ទិនទៅនឹងបញ្ហាពាក់ព័ន្ធទាំងអស់ ដែលឆ្លុះបញ្ចាំងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរសំណុំរឿង ០០៣"[121]។ សហមេធាវីស្នើឡើងថា ទាក់ទិននឹងសំណើនេះ *វិធាន ២១ នៃវិធានផ្ទៃក្នុង តម្រូវឲ្យមានការទទួលយកបណ្តឹងឧទ្ធរណ៍* ដើម្បីការពារសិទ្ធិរបស់ [redacted] ក្នុងការទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីត្រៀមរៀបចំការពារខ្លួនរបស់គាត់ និងសិទ្ធិក្នុងការទទួលបាន

---

[120] សំណើរបស់ [redacted] ស្នើសុំការបញ្ជាក់ ពាក់ព័ន្ធនឹងថាតើ មេធាវីការពារក្តីអាចធ្វើការស៊ើបអង្កេតនៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនាពេលបច្ចុប្បន្ននេះ ឬយ៉ាងណា ថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D87/2/1.12។

[121] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៩(ង)។

នូវសមភាពនៃមធ្យោបាយក្នុងការតទល់ក្តី[122]។ នៅក្នុងសំណើ សហមេធាវីស្នើឱ្យសហចៅក្រមស៊ើបអង្កេត "បញ្ជាក់ថាតើ មេធាវីការពារក្តីអាចធ្វើការស៊ើបអង្កេត នៅក្នុងអំឡុងដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនាពេលបច្ចុប្បន្ននេះ ឬយ៉ាងណា"[123]។ ដោយបានកត់សម្គាល់នូវការបញ្ជាក់បំភ្លឺរបស់សហចៅក្រមស៊ើបអង្កេត ដែលបានផ្ញើជូនទៅកាន់ភាគីទាំងអស់នៃការស៊ើបអង្កេតក្នុងសំណុំរឿង ០០២ ដែលថា "នៅចំពោះមុខតុលាការនេះ អំណាចបើកកិច្ចស៊ើបសួរត្រូវបានផ្តល់ឱ្យផ្តាច់មុខទៅសហចៅក្រមស៊ើបអង្កេតឯករាជ្យទាំងពីររូប និងមិនផ្តល់ឱ្យ*ភាគីទ*"[124] សហមេធាវីលើកទឡ្ហីករណ៍ថា កាលៈទេសៈរបស់មេធាវីការពារក្តី [redacted] "មានភាពខុសគ្នាយ៉ាងច្រើន" ពីព្រោះ ដូចដែលសហមេធាវីបានលើកឡើង [redacted] *"មិនត្រូវបានចាត់ទុកជាភាគី"* និង *"ពុំមានសិទ្ធិក្នុងការចូលទៅពិនិត្យមើលសំណុំរឿងឡើយ"* ដូច្នេះហើយការបញ្ជាក់បំភ្លឺ ដែលបានដកស្រង់ខាងលើនេះ មិនអាចយកមកអនុវត្តចំពោះ [redacted] ដែលមិនមែនជាភាគីនោះឡើយ។ ដោយធ្វើការប្រៀបធៀបជាមួយនឹងសកម្មភាពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា សហមេធាវីលើកទឡ្ហីករណ៍ថា *អ្នកដែលមិនមែនជាភាគី* មិនត្រូវបានកំហិតសិទ្ធិមិនឱ្យស៊ើបអង្កេតនោះទេ ហើយថាលើសពីនេះទៀត [redacted] ដែលជាគោលដៅនៃការស៊ើបអង្កេត ប៉ុន្តែមិនមែនជាភាគីនោះ គួរត្រូវបានអនុញ្ញាតឱ្យធ្វើការស៊ើបអង្កេត*ដោយឯករាជ្យ*[125]។

46. អង្គបុរេជំនុំជម្រះយល់ឃើញថា ដោយមិនប៉ះពាល់ដល់ឋានៈរបស់ [redacted] នៅក្នុងកិច្ចដំណើរការនីតិវិធីស៊ើបអង្កេត ពុំមានបទបញ្ញត្តិណាមួយនៃច្បាប់ជាធរមាន ដែលផ្តល់សិទ្ធិឱ្យភាគី ឬអ្នកមិនមែនភាគីនៃបញ្ហានេះ បំពេញកិច្ចស៊ើបសួរ ជំនួសសហចៅក្រមស៊ើបអង្កេតដែលទទួលបន្ទុកនៅក្នុងកិច្ចស៊ើបសួរនោះទេ។ លើសពីនេះទៀត ទាក់ទិននឹងភាគី អង្គបុរេជំនុំជម្រះក៏បានយល់ស្របផងដែរជាមួយនឹងសហចៅក្រមស៊ើបអង្កេត ដោយបញ្ជាក់ថា "ដូច្នេះ សមត្ថភាពរបស់ភាគីក្នុងការចូលពាក់ព័ន្ធ *ត្រូវបានកំហិតទៅត្រឹមការស្នើសុំដំបូងនេះ ដែលជាការចាំបាច់ ដើម្បីឱ្យពួកគាត់អាចអនុវត្តសិទ្ធិរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ក្នុងការស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរ"* និង

---

[122] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៣។ សូមមើលផងដែរ ឯកសារ D87/2/1.12 កថាខណ្ឌ សេចក្តីផ្តើម។

[123] ឯកសារ D87/2/1.12 កថាខណ្ឌ ១៩។

[124] ឯកសារ D87/2/1.12 កថាខណ្ឌ ១៥ យោងទៅសំណុំរឿង ០០២ លិខិតពី ក.ស.ច.ស ផ្ញើជូនមេធាវីការពារក្តី យោង៖ ចម្លើយតបទៅនឹងលិខិតរបស់លោក ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៧ ស្តីអំពីការធ្វើកិច្ចស៊ើបអង្កេត ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៨ ឯកសារ A110/1 ទំព័រ ២។

[125] ឯកសារ D87/2/1.12។

ទាញចំណាប់អារម្មណ៍របស់សហមេធាវីទៅបទបញ្ញត្តិនៃវិធាន ៣៥ នៃវិធានផ្ទៃក្នុង (ការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ) និងវិធាន ៣៨ (កំហុសវិជ្ជាជីវៈរបស់មេធាវី) នៃ អ.វ.ត.ក ក្នុងករណីអាចអនុវត្តបាន[126]។ អង្គបុរេជំនុំជម្រះក៏សូមឱ្យយកចិត្តទុកដាក់ផងដែរទៅលើចំណុចដែលថា បទបញ្ញត្តិនៃវិធាន ៣៥ នៃវិធានផ្ទៃក្នុង អនុវត្តចំពោះ "ជនណាក៏ដោយ"។ ដោយសារតែ សហមេធាវីរបស់ [redacted] ធ្លាប់ធ្វើជាសហមេធាវីតំណាងឱ្យ អៀង សារី នៅក្នុងសំណុំរឿង ០០២ ផងដែរនោះ ពួកគាត់ប្រាកដជាបានដឹងច្បាស់អំពីការប្រកាសទាំងនេះ និងអំពីច្បាប់ជាធរមាននៅចំពោះមុខ អ.វ.ត.ក។

47. ដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា ក្នុងខណៈដែលកិច្ចស៊ើបសួរកំពុងតែដំណើរការនោះ ការយឺតយ៉ាវក្នុងការឆ្លើយតបរបស់ ក.ស.ច.ស ចំពោះសំណើនេះ មិនបានរំលោភលើសិទ្ធិជាសារវ័ន្តរបស់ [redacted] ។ ដូច្នេះ បណ្តឹងឧទ្ធរណ៍នេះមិនអាចទទួលយកបាន ដោយផ្អែកមូលដ្ឋានលើការបដិសេធតាមការសន្មត ឬបើមិនដូច្នោះទេអនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុងនោះឡើយ។

**ញត្តិប្រឆាំងនឹងការអនុវត្តឧក្រិដ្ឋកម្មនានាដែលមានចែងនៅក្នុងមាត្រា ៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក (ឧក្រិដ្ឋកម្មដែលចែងក្នុងច្បាប់ជាតិ)[127]**

48. សហមេធាវីលើកឡើងថា ញត្តិនេះធ្វើឡើងជាការចាំបាច់ ហើយថា ទាក់ទិននឹងញត្តិនេះ *វិធាន ២១ នៃវិធានផ្ទៃក្នុង* តម្រូវឱ្យទទួលយកបណ្តឹងឧទ្ធរណ៍ "ពីព្រោះការយកមាត្រា ៣ ថ្មី មកអនុវត្តនោះនឹងរំលោភលើសិទ្ធិរបស់លោក [redacted] *ក្នុងការទទួលបាននូវការប្រព្រឹត្តិស្មើភាពគ្នានៅចំពោះមុខ អ.វ.ត.ក*"[128]។ នៅក្នុងសំណើនេះ សហមេធាវីស្នើឱ្យសហចៅក្រមស៊ើបអង្កេត "*បដិសេធ*

---

[126] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស ពាក់ព័ន្ធនឹងរដ្ឋបរទេស ថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារ D315/1/5 កថាខណ្ឌ ១៥។

[127] ញត្តិរបស់ [redacted] ប្រឆាំងនឹងការអនុវត្តឧក្រិដ្ឋកម្មនានាដែលមានចែងនៅក្នុងមាត្រា ៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក (ឧក្រិដ្ឋកម្មដែលចែងក្នុងច្បាប់ជាតិ) ថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D87/2/1.13។

[128] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៩(ឋ) និង ២៣។ សូមមើលផងដែរ ឯកសារ D87/2/1.13 កថាខណ្ឌ សេចក្តីផ្តើម។ សហមេធាវីពន្យល់ថា "សិទ្ធិរបស់ជនជាប់ចោទនៅ អ.វ.ត.ក ក្នុងការ*ទទួលបានការប្រព្រឹត្តស្មើគ្នាទៅនឹងជនជាប់ចោទនៅក្នុងតុលាការកម្ពុជាផ្សេងទៀត*" នឹងមិនត្រូវបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍នេះទេ។ សហមេធាវីក៏បញ្ជាក់ផងដែរថា ពួកគេនឹងមិនលើកឡើងនៅក្នុងសំណើនេះនូវទឡ្ហីករណ៍របស់ខ្លួនដែលថា *ការអនុវត្ត*មាត្រា ៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក រំលោភគោលការណ៍ប្រតិសកម្មឡើយ។

00983224



*កុំយកឧក្រិដ្ឋកម្មតាមច្បាប់ជាតិ* ដែលមានចែងនៅក្នុងមាត្រា ៣(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មកអនុវត្តចំពោះ [redacted]"[129]។ សហមេធាវីលើកទឡ្ហីករណ៍ថា ការយកមាត្រា ៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មកអនុវត្តនោះ នឹងរំលោភលើសិទ្ធិរបស់ [redacted] ក្នុងការទទួលបាននូវការប្រព្រឹត្តិស្មើភាពគ្នានៅចំពោះមុខច្បាប់ ដែលត្រូវបានធានានៅក្នុងមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា មាត្រា ៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ៧ នៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស និងមាត្រា ១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ICCPR")[130]។ សហមេធាវីលើកឡើងថា ដោយសារតែ "*ការអនុវត្ត* មាត្រា ៣ ថ្មី [នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក] *ត្រូវបានបដិសេធនៅក្នុងសំណុំរឿង ០០១ និង ០០២ ដោយសារបញ្ហាផ្លូវច្បាប់សុទ្ធសាធ*" នោះ "ពុំមានលក្ខខណ្ឌវិនិច្ឆ័យសមហេតុផល ឬសត្យានុម័ត ដែលអនុញ្ញាតឱ្យ*យកមាត្រា ៣ ថ្មី មកអនុវត្តប្រឆាំងលោក* [redacted] ទេ នៅពេលដែលមាត្រានេះ *មិនអាចត្រូវបានយកមកអនុវត្ត* ប្រឆាំងនឹង ឌុច, នួន ជា, អៀង សារី, អៀង ធីរិទ្ធ ឬ ខៀវ សំផន នោះ"[131]។

49. ជាដំបូង អង្គបុរេជំនុំជម្រះកត់សម្គាល់ថា នៅក្នុងសំណើមានលក្ខណៈមិនច្បាស់ឡើយ ចំពោះថាតើសហមេធាវីចង់មានន័យយ៉ាងដូចម្តេចនៅពេលលើកឡើងថា "*ការអនុវត្ត* មាត្រា ៣ ថ្មី ត្រូវបានបដិសេធ ដោយសារបញ្ហាផ្លូវច្បាប់"។ ទោះបីជាយ៉ាងណាក៏ដោយ អង្គបុរេជំនុំជម្រះកត់សម្គាល់ថាសហមេធាវីពន្យល់ថា ពួកគាត់នឹងមិនលើកឡើងនៅក្នុងសំណើនេះនូវទឡ្ហីករណ៍របស់ខ្លួនដែលថា *ការអនុវត្ត* មាត្រា ៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក រំលោភគោលការណ៍ប្រតិសកម្មឡើយ។

50. អង្គបុរេជំនុំជម្រះកត់សម្គាល់បន្ថែមទៀតថា នៅក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះសាលាដំបូង *មិនអាចពិចារណាអំពីពិរុទ្ធភាព*[132]របស់ ឌុច ពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋតាមច្បាប់ជាតិឡើយ ដោយសារតែអង្គជំនុំជម្រះ "*មិនបានឈានទៅដល់ការឯកភាពគ្នា* ថាតើថិរវេលានៃអាជ្ញាយុកាលដែលអាចអនុវត្តត្រូវបានពន្យារ ឬមិនបានពន្យារ ក្នុងចន្លោះឆ្នាំ ១៩៧៩ និងឆ្នាំ ១៩៩៣ និង ថាតើរយៈពេលនេះ

[129] ឯកសារ D87/2/1.13 កថាខណ្ឌ៤៤។

[130] ឯកសារ D87/2/1.13 កថាខណ្ឌ ៣៨។

[131] ឯកសារ D87/2/1.13 កថាខណ្ឌ ៤២។

[132] សាលក្រម ក្នុងសំណុំរឿង ០០១ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ ឯកសារ E188 អង្គជំនុំជម្រះសាលាដំបូង (សាលក្រម ក្នុងសំណុំរឿង ០០១) កថាខណ្ឌ ៦៧៨។

ត្រូវបានផុតរលត់មុនពេលដែលមាត្រា ៣ និងមាត្រា ៣ថ្មី ត្រូវបានប្រកាស ឲ្យប្រើដែរឬទេ"[133]។ ការដែលអង្គជំនុំជម្រះសាលាដំបូងមិនបានឈានទៅដល់ការឯកភាពគ្នានោះ មិនបានបញ្ជាក់ថា អ.វ.ត.ក មិនមែនគ្រាន់តែជា *អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក* មិនអាចអនុវត្ត ឬពុំមានយុត្តាធិការទៅលើបទឧក្រិដ្ឋតាមច្បាប់ជាតិនោះឡើយ៖ "ហេតុដូច្នេះការដែលចៅក្រមមិនអាចរកសំឡេងភាគច្រើនតាមច្បាប់តម្រូវបាននោះ គឺបង្កើតជាឧបសគ្គក្នុង*ការបន្តការវិនិច្ឆ័យ* លើជនជាប់ចោទចំពោះបទឧក្រិដ្ឋតាមច្បាប់ជាតិនៅចំពោះមុខ*អង្គជំនុំជម្រះសាលាដំបូង* នៃ អ.វ.ត.ក"[134]។ លើសពីនេះទៀត អង្គបុរេជំនុំជម្រះកត់សម្គាល់ចំណុចដែលថា អង្គជំនុំជម្រះសាលាដំបូងបានសម្រេចនៅក្នុងសាលក្រមក្នុងសំណុំរឿង ០០១ ថា "*ឧក្រិដ្ឋកម្មទាំងនាដែលចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ [ដែលរួមបញ្ចូលទាំងបទឧក្រិដ្ឋតាមច្បាប់ជាតិ] គឺស្ថិតនៅក្នុងដែនកំណត់នៃយុត្តាធិការលើរឿងក្តី យុត្តាធិការក្នុងពេលវេលា និងយុត្តាធិការលើដែនដីរបស់ អ.វ.ត.ក*"[135]។

51. នៅក្នុងសំណុំរឿង ០០២ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនលើអញ្ញត្រកម្មនានារបស់មេធាវីការពារក្តី ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូង ដោយហេតុថាដីកាដំណោះស្រាយ *មានវិការៈ ដោយសារអង្គហេតុមិនគ្រប់គ្រាន់* នៅក្នុងដីកាដំណោះស្រាយ ពាក់ព័ន្ធនឹងបទឧក្រិដ្ឋតាមច្បាប់ជាតិនោះ យល់ឃើញថា *អង្គជំនុំជម្រះពុំចាំបាច់សម្រេចទៅលើខ្លឹមសារនៃអញ្ញត្រកម្មនានា ទាក់ទិននឹងភាពអាចអនុវត្តបាននៃមាត្រា៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ឡើយ*[136]។ ការណ៍ដែលថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនេះ មិនត្រូវបានប្តឹងសាទុក្ខនៅពេលដែលសេចក្តីសម្រេចនោះចេញ មិនមែនមានន័យថា សេចក្តីសម្រេចនោះមិនអាចត្រូវបានប្តឹង

---

[133] សេចក្តីសម្រេចស្តីពីការជំទាស់ជាបឋមរបស់មេធាវីការពារក្តី ពាក់ព័ន្ធនឹងអាជ្ញាយុកាលនៃបទល្មើសជាតិ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ ឯកសារ E187 (សេចក្តីសម្រេចស្តីពីការជំទាស់ជាបឋមរបស់មេធាវីការពារក្តី ក្នុងសំណុំរឿង ០០១) កថាខណ្ឌ ១៤។

[134] សេចក្តីសម្រេចស្តីពីការជំទាស់ជាបឋមរបស់មេធាវីការពារក្តី ក្នុងសំណុំរឿង ០០១ ឯកសារ E 187 កថាខណ្ឌ ៥៦។

[135] សាលក្រម ក្នុងសំណុំរឿង ០០១ កថាខណ្ឌ ១៦ និង ១១។

[136] សេចក្តីសម្រេចស្តីពីការជំទាស់ជាបឋមរបស់មេធាវីការពារក្តី ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារ E 122 កថាខណ្ឌ ២៣។

សាទុក្ខនៅស្របពេលជាមួយនឹងបណ្តឹងសាទុក្ខ ប្រឆាំងនឹងសាលក្រមលើអង្គសេចក្តីក្នុងសំណុំរឿង ០០២ នោះឡើយ[137]។

52. សរុបសេចក្តីមក អង្គហេតុទាំងនេះមិនត្រូវបានចាត់ទុកថាជាសេចក្តីសន្និដ្ឋានថា "ការអនុវត្តមាត្រា ៣ថ្មី *ត្រូវបានបដិសេធ ដោយសារបញ្ហាផ្លូវច្បាប់* នៅក្នុងសំណុំរឿង ០០១ និង ០០២" ដូចដែលសហមេធាវីលើកឡើងនៅក្នុងសំណើនោះឡើយ។ លើសពីនេះទៀត អង្គបុរេជំនុំជម្រះ ទាំងនៅក្នុងសំណុំរឿង ០០១ និង ០០២ បានបញ្ជាក់នៅក្នុងសេចក្តីសម្រេចដោយមានសំអាងហេតុយ៉ាងពេញលេញថា អ.វ.ត.ក មានយុត្តាធិការលើបទឧក្រិដ្ឋតាមច្បាប់ជាតិ[138]។ ទោះបីជាដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ មានវិការៈ ដូចដែលសហមេធាវីបានលើកឡើង "ដោយសារតែសហចៅក្រមស៊ើបអង្កេតមិនយល់ស្របគ្នាចំពោះភាពអាចអនុវត្តបាននៃមាត្រា ៣ ថ្មី"[139] ក៏នៅក្នុងសាលដីកាលើបណ្តឹងឧទ្ធរណ៍ អង្គបុរេជំនុំជម្រះយល់ឃើញថា អ.វ.ត.ក មានយុត្តាធិការលើបទឧក្រិដ្ឋតាមច្បាប់ជាតិ ហើយដោយផ្អែកលើមូលដ្ឋាននេះ បានខិតខំប្រឹងប្រែង*ជួសជុលវិការៈ* នៅក្នុងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត ដោយចង្អុលបង្ហាញទៅអង្គហេតុជាធរមាន[140]។ កង្វះខាតអង្គហេតុដែលអនុញ្ញាតឲ្យអង្គជំនុំជម្រះមួយកំណត់បទឧក្រិដ្ឋថាជាបទឧក្រិដ្ឋតាមច្បាប់ជាតិ ដូចដែលមានចែងនៅក្នុងមាត្រា ៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក នៅក្នុងរឿងក្តីមួយប្រឆាំងនឹងចុងចម្លើយម្នាក់ មិនមែនមានន័យថា មាត្រា ៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មិនអាចយកមកអនុវត្តនៅក្នុងរឿងក្តីមួយទៀត ប្រឆាំងនឹងចុងចម្លើយម្នាក់ផ្សេងទៀតបាននោះឡើយ ប្រសិនបើអង្គហេតុបែបនោះមានអត្ថិភាព។ ទោះបីជា អ.វ.ត.ក មានយុត្តាធិការលើបទឧក្រិដ្ឋតាមច្បាប់ជាតិក៏ដោយ ដើម្បីធានានូវការប្រព្រឹត្តិដោយស្មើភាពគ្នានៅ

---

[137] វិធាន ១០៤(៤) នៃវិធានផ្ទៃក្នុង។

[138] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ២៧៨-២៩២, ២៩៧។ សូមមើលផងដែរ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ កាំង ហ្គេចអ៊ាវ ហៅ "ឌុច" ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០០៨ ឯកសារ D99/3/42 កថាខណ្ឌ ៨៩-៩៥។

[139] ឯកសារ D87/2/1.13 កថាខណ្ឌ ៤៣។

[140] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ២៩៣-២៩៦។ កត់សម្គាល់ផងដែរថា អង្គបុរេជំនុំជម្រះមានអំណាចសម្រេចចុងក្រោយ ទាក់ទិននឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ប្រសិនបើដីកាដំណោះស្រាយត្រូវបានប្តឹងឧទ្ធរណ៍ ហើយថា នៅក្នុងករណីបែបនេះ អង្គជំនុំជម្រះសាលាដំបូងទទួលបានទាំងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត និងសាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍។

ចំពោះមុខ អ.វ.ត.ក មាត្រា ៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ត្រូវតែយកមកអនុវត្តនៅក្នុងលក្ខណៈដូចគ្នាចំពោះជនទាំងឡាយដែលស្ថិតនៅក្រោមមាត្រានេះ។ នេះមានន័យថា ពិរុទ្ធភាពរបស់ជនទាំងឡាយដែលត្រូវបានយកមកជំនុំជម្រះនៅចំពោះមុខ អ.វ.ត.ក ដោយសារតែការចោទប្រកាន់ថាបានប្រព្រឹត្តបទឧក្រិដ្ឋតាមច្បាប់ជាតិនោះ អាចត្រូវបានយកមកពិចារណា តែក្នុងករណីដែលអង្គហេតុនៃបទឧក្រិដ្ឋទាំងនោះត្រូវរកឃើញតាមរយៈការស៊ើបអង្កេត និងមានចែងយ៉ាងត្រឹមត្រូវនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលអនុញ្ញាតឱ្យមានការកំណត់ប្រភេទនៃបទល្មើសសមស្របចំពោះបទឧក្រិដ្ឋទាំងនោះ។ ទាក់ទិននឹងបញ្ហានេះ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ការស៊ើបអង្កេតក្នុងសំណុំរឿង ០០៣ កំពុងតែដំណើរការ ហើយថា ច្បាប់ជាធរមានមិនតម្រូវឱ្យសហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចធ្វើការកំណត់ប្រភេទនៃបទល្មើសនៃអង្គហេតុនានាដែលខ្លួនរកឃើញក្នុងអំឡុងការស៊ើបអង្កេតឡើយ។ កាតព្វកិច្ចបែបនេះ ប្រសិនបើមាន កើតមានតែក្នុងករណីដែលមានការចេញដីកាដំណោះស្រាយប៉ុណ្ណោះ។

53. ដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា សំណើនេះគឺជាការប្រញាប់ប្រញាល់ពេក ដូច្នេះហើយមិនតម្រូវឱ្យមានការទទួលយកបណ្តឹងឧទ្ធរណ៍នេះ ដោយផ្អែកមូលដ្ឋានលើការបដិសេធតាមការសន្មត ឬបើមិនដូច្នោះទេអនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុងឡើយ។

**ញត្តិប្រឆាំងនឹងការអនុវត្តសហឧក្រិដ្ឋកម្មរួមទម្រង់ទូលាយ (JCE III)[141]**

54. សហមេធាវីលើកឡើងថា ញត្តិនេះធ្វើឡើងជាការចាំបាច់ "ដោយសារតែដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ចោទប្រកាន់ថា [redacted] ជាជម្រើសទទួលខុសត្រូវចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្មតាមរយៈ JCE III ដែលជាទម្រង់នៃការទទួលខុសត្រូវមួយមិនត្រូវបានទទួលស្គាល់នៅ អ.វ.ត.ក"[142]។ សហមេធាវីលើកទឡ្ហីករណ៍ថា ទាក់ទិននឹងញត្តិនេះ វិធាន ២១ នៃវិធានផ្ទៃក្នុងតម្រូវឱ្យមានការទទួលយកបណ្តឹងឧទ្ធរណ៍ ដើម្បីការពារសិទ្ធិរបស់ [redacted] ក្នុងការទទួលបាននូវកិច្ចដំណើរការនីតិវិធីប្រកបដោយយុត្តិធម៌ និងតម្លាភាព[143]។ នៅក្នុងសំណើ សហមេធាវីស្នើ

[141] ញត្តិរបស់ [redacted] ប្រឆាំងនឹងការអនុវត្ត សហឧក្រិដ្ឋកម្មរួមទម្រង់ទូលាយ (JCE III) ថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D87/2/1.15។

[142] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៩ (ឃ)។

[143] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៣។ សូមមើលផងដែរ ឯកសារ D87/2/1.15 កថាខណ្ឌ សេចក្តីផ្តើម។

ឱ្យសហចៅក្រមស៊ើបអង្កេត បដិសេធការអនុវត្ត JCE III ប្រឆាំងនឹង [redacted][144] ពីព្រោះទាំងអង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូង បានយល់ឃើញថា JCE III មិនអាចអនុវត្តបាននៅ អ.វ.ត.ក ហើយពីព្រោះការសម្រេចរបស់អង្គជំនុំជម្រះទាំងនោះ ចងកាតព្វកិច្ច ហើយសហព្រះរាជអាជ្ញាមិនបានប្ដឹងសាទុក្ខ ប្រឆាំងនឹងការសម្រេចនេះរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២ ឡើយ។ សហមេធាវីបន្ថែមថា ការយក JCE III មក អនុវត្តទៅលើ [redacted] ក៏នឹងរំលោភទៅលើសិទ្ធិរបស់គាត់ ក្នុងការទទួលបានការប្រព្រឹត្តដោយស្មើភាពគ្នាដែរ។

55. ជាការកត់សម្គាល់បឋម អង្គបុរេជំនុំជម្រះកត់សម្គាល់ថា អង្គហេតុដែលថាសហព្រះរាជអាជ្ញាមិនបានប្ដឹងសាទុក្ខទៅនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង[145] លើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម នៅពេលដែលសេចក្ដីសម្រេចនោះចេញ មិនមែនមានន័យថា សេចក្ដីសម្រេចនោះមិនអាចត្រូវបានប្ដឹងសាទុក្ខ នៅពេលស្របជាមួយនឹងបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមលើអង្គសេចក្ដី ក្នុងសំណុំរឿង ០០២ នោះឡើយ។

56. លើសពីនេះទៀត អង្គបុរេជំនុំជម្រះយល់ឃើញថា ញត្តិនេះគឺជាការប្រញាប់ប្រញាល់ពេក ដោយសារតែវិធានផ្ទៃក្នុងមិនចងកាតព្វកិច្ចសហចៅក្រមស៊ើបអង្កេតក្នុងការសម្រេច ឬធ្វើសេចក្ដីបញ្ជាក់បកស្រាយច្បាប់ស្ដីអំពីបញ្ហាយុត្តាធិការ មុនពេលសហចៅក្រមស៊ើបអង្កេតចេញដីកាដំណោះស្រាយ ប្រសិនបើមានដីកាដំណោះស្រាយនោះ។ លើសពីនេះទៀត ប្រសិនបើដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០៣ ប្រសិនបើមានដីកានេះ បញ្ជាក់ពីយុត្តាធិការរបស់ អ.វ.ត.ក នៅក្នុងលក្ខណៈដែលអាចប៉ះពាល់ដល់សិទ្ធិរបស់ពួកគាត់ ជនត្រូវចោទ ដូចបានបង្ហាញរួចហើយនៅក្នុងយុត្តិសាស្ត្រ អាចពិចារណាអំពីអានុភាពវិធាន ៦៧(៥) និងវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុងនៅពេលអានវិធានទាំងពីរនេះរួមគ្នា។

57. ដោយយោងទៅលើហេតុផលទាំងនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា សិទ្ធិជាសារវន្តរបស់ [redacted] មិនត្រូវបានប៉ះពាល់ ដោយការប្រកាសមិនទទួលយកបណ្ដឹងឧទ្ធរណ៍ *នៅក្នុងដំណាក់កាលនេះនៃកិច្ចដំណើរការនីតិវិធី* ទេ ហើយវិធាន ២១ នៃវិធានផ្ទៃក្នុង មិនបានចាប់បង្ខំឱ្យអង្គបុរេជំនុំ

[144] ឯកសារ D87/2/1.15 កថាខណ្ឌ ២៦។

[145] ឯកសារ E100/6។

ជម្រះសម្រេចទទួលយកបណ្តឹងឧទ្ធរណ៍នេះ ដោយផ្អែកមូលដ្ឋានលើការបដិសេធតាមការសន្និត ឬដោយសារហេតុផលផ្សេងទៀតដែលមានចែងនៅក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុងនោះឡើយ។

## IV. សេចក្តីសម្រេច

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទថា៖**

**ពន្យារពេល**ការធ្វើសេចក្តីសម្រេចទៅលើបណ្តឹងឧទ្ធរណ៍ ទាក់ទិននឹងសំណើសុំចូលពិនិត្យមើលសំណុំរឿង រហូតដល់អង្គបុរេជំនុំជម្រះសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចពាក់ព័ន្ធនឹងទំនាស់។

**បណ្តឹងឧទ្ធរណ៍មិនអាចទទួលយកបាន** ទាក់ទិននឹងសំណើផ្សេងៗទៀត។

**រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៤**

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គិមស្រេង** **Rowan DOWNING** **ន័យ ថុល** **Chang-ho CHUNG** **ហួត វុទ្ធី**